مدرسة اهل البيت

# សាលា
# អាស្ហ់លុល-បៃត៍

## សៀវភៅ ហ្វីក្ហេះហ្ហ៍ ថ្នាក់ទី ៨ (អាយុ ១២-១៣ ឆ្នាំ)

រ៉ស្ហូលុលឡោះហ្ហ៍ﷺមានព្រះវចនៈថា៖ "ការស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចរបស់មុស្លីមីនប្រុសស្រីគ្រប់រូប ។"

## សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ - ស្វ៏ឡាត់ - ស្វ៏ឡាត់ យ៉ាម៉ាអ៊ុស្ស(១) ........ ៤

មេរៀនទី ២ - ស្វ៏ឡាត់ - ស្វ៏ឡាត់ យ៉ាម៉ាអ៊ុស្ស(២) ........ ៧

មេរៀនទី ៣ - ណាយ៉ាសាស្ស ........ ១១

មេរៀនទី ៤ - គ៊ុសល៍ (ឬ គ៊ុស្វ៊ល غسل) ........ ១៤

មេរៀនទី ៥ - បែបបទក្នុងការបន្ទោបង់ ........ ១៦

មេរៀនទី ៦ - មូតោះហ្វ៊ីរ៉ត់(១) ........ ១៨

មេរៀនទី ៧ - មូតោះហ្វ៊ីរ៉ត់(២) ........ ២១

មេរៀនទី ៨ - ស្វ៏ឡាត់ យ៉ុមអ៊ុត់ (ស្វ៏ឡាត់ ថ្ងៃសុក្រ) ........ ២៤

មេរៀនទី ៩ - ស្វ៏ឡាទុល អ៊ីដៃន៍ (ស្វ៏ឡាត់ អ៊ីដទាំងពីរ) ........ ២៧

មេរៀនទី ១០ - ស្វ៊ីហ្វាត់ ស្សុ៊ប៊ូទីយ៉ាស្ស (الصفات الثبوتية) ........ ៣០

មេរៀនទី ១១ - ម៉ាសាអ៊ីល(مسائل) យ៉ាប៊ីរ៉ោះត៍ (جبيرة) ........ ៣៣

មេរៀនទី ១២ - ពាក្យបច្ចេកទេសអ៊ិស្លាម ........ ៣៧

មេរៀនទី ១៣ - អាស្ស់កាមុល អ៊ិសទីបរ៉អ៍ (احكام الاستبراء) ........ ៣៩

លំហាត់ ១ ........ ៤១

លំហាត់ ២ ........ ៤១

លំហាត់ ៣ ........ ៤២

លំហាត់ ៤ ........ ៤៤

លំហាត់ ៦ ........ ៤៦

លំហាត់ ៧ ........ ៤៨

លំហាត់ ៨ និង ៩ ........ ៤៩

លំហាត់ ១០ ........ ៥៣

លំហាត់ ១១ ........ ៥៥

**មេរៀនទី ១**

# ស្វ៉ូឡាត់ - ស្វ៉ូឡាត់យ៉ាម៉ាអាស់

(صلاة الجماعة)

**ផលប្រយោជន៍ផ្លូវធម៌និងផ្លូវសម្ភារៈ**

ស្វ៉ូឡាត់យ៉ាម៉ាអាស់មានន័យថាបំពេញនមស្ការជុំគ្នា ។ មគ្គផលច្រើនណាស់ពេលណាស្វ៉ូឡាត់ត្រូវបំពេញជាស្វ៉ូឡាត់យ៉ាម៉ាអាស់ ។ វាផ្តល់ឲ្យយើងនូវអត្ថប្រយោជន៍ផ្លូវធម៌ក៏ដូចផ្លូវសម្ភារៈដែរ ។

**១-ភាពស្មើគ្នាក្នុងសាសនាអ៊ីស្លាម**

ការប្រជុំគ្នា អ្នកមាននិងក្រ ខ្ពស់ទាប ទាំងអស់គ្នាក្រោកឈរ ស្មាទល់ស្មា ។ ជាទិដ្ឋភាពប្រសើរបំផុតដែលឆ្លុះបញ្ចាំងនូវភាពស្មើគ្នានៃមនុស្ស ។

**២-ឯកភាព**

ក្នុងស្វ៉ូឡាត់នេះ ទាំងអស់គ្នាមាននៀតតែមួយ ភាសាតែមួយ ទង្វើតែមួយ ។ បង្អោនកាយជាមួយគ្នា ក្រាបប្រណិប័តន៍ជាមួយគ្នា ។ នេះជាមេរៀនមួយរបស់យើងគឺៈ ជាមុស្លីម យើងត្រូវឯកភាពគ្នាគ្រប់ពេល ។

**៣-សេចក្តីស្រឡាញ់និងសហប្រតិបត្តិការ**

មនុស្សជួបគ្នាក្នុងពេលស្វ៉ូឡាត់យ៉ាម៉ាអាស់ ។ គេឲ្យដំណឹងគ្នាទៅវិញទៅមកអំពីសេចក្តីលំបាកនិងសេចក្តីបារម្ភ ហើយព្យាយាមជួយគ្នាទៅវិញទៅមក ។ គេទទួលបាននូវព័ត៌មានថ្មីៗក្នុងពេលស្វ៉ូឡាត់យ៉ាម៉ាអាស់ ។ សេចក្តីស្រឡាញ់គ្នាទៅវិញទៅ

មករីកចម្រើនឡើងនៅក្នុងពេលស្វ៍ឡាត់យ៉ាម៉ាអាស់ ។ រង្វង់មិត្តភាពកាន់តែវាតទំហំនៅពេលនោះ ។ នៅពេលនោះយើងអាចមានឱកាសអាចធ្វើឲ្យជីវិតយើងកាន់តែប្រសើរឡើង ដោយអាស្រ័យលើបទពិសោធន៍របស់អ្នកឯទៀត ។

**៤-វិន័យ**

ពេលយើងស្វ៍ឡាត់យ៉ាម៉ាអាស់ យើងតម្រង់ជួរ តាមអ៊ីម៉ាំយ៉ាម៉ាអាស់ និងគោរពបូជាអល់ឡោះហ៍ ។ វាធ្វើឲ្យមានការគោរពវិន័យដែលជាកត្តាចាំបាច់ក្នុងជីវភាពសហគមន៍ ។

**៥-កិត្យានុភាពរបស់អ៊ីស្លាម**

ម៉ាស់យ៉ីដ្ធយើងរុងរឿងដោយសារស្វ៍ឡាត់យ៉ាម៉ាអាស់ ធ្វើឲ្យកិត្យានុភាពមុស្លីមកាន់តែមានឡើង ឯកភាពមុស្លីមធ្វើឲ្យសត្រូវញញើត ។

**៦-រង្វាន់ឥតព្រំដែន**

អល់ឡោះហ៍បានដាក់រង្វាន់យ៉ាងធំសម្រាប់ស្វ៍ឡាត់យ៉ាម៉ាអាស់ ។ ព្រះសាស្តាﷺ យើងនិងព្រះសន្តអ៊ីម៉ាំعليه السلامមានព្រះវចនៈអន្ទោកអន្ទោល អំពីស្វ៍ឡាត់យ៉ាម៉ាអាស់ ។ ដូច្នេះយើងគប្បីបំពេញស្វ៍ឡាត់យ៉ាម៉ាអាស់ឲ្យបានញឹកញយ តាមដែលអាចធ្វើទៅបាន ។

បើស្វ៍ឡាត់យ៉ាម៉ាអាស់មានគ្នា ២ នាក់ រ៉ក់អាត់នីមួយៗស្មើ ៥០ ស្វ៍ឡាត់ ។
បើស្វ៍ឡាត់យ៉ាម៉ាអាស់មានគ្នា ៣ នាក់ រ៉ក់អាត់នីមួយៗស្មើ ៦០០ ស្វ៍ឡាត់ ។
បើស្វ៍ឡាត់យ៉ាម៉ាអាស់មានគ្នា ៤ នាក់ រ៉ក់អាត់នីមួយៗស្មើ ១២០០ ស្វ៍ឡាត់ ។
បើស្វ៍ឡាត់យ៉ាម៉ាអាស់មានគ្នា ៥ នាក់ រ៉ក់អាត់នីមួយៗស្មើ ២៤០០ ស្វ៍ឡាត់ ។
បើស្វ៍ឡាត់យ៉ាម៉ាអាស់មានគ្នា ៦ នាក់ រ៉ក់អាត់នីមួយៗស្មើ ៤៨០០ ស្វ៍ឡាត់ ។
បើស្វ៍ឡាត់យ៉ាម៉ាអាស់មានគ្នា ៧ នាក់ រ៉ក់អាត់នីមួយៗស្មើ ៩៦០០ ស្វ៍ឡាត់ ។
បើស្វ៍ឡាត់យ៉ាម៉ាអាស់មានគ្នា ៨ នាក់ រ៉ក់អាត់នីមួយៗស្មើ ១៩២០០ ស្វ៍ឡាត់ ។

បើស្វ៏ឡាត់យ៉ាម៉ាអុស់មានគ្នា ៩ នាក់ រ៉ក់អាត់នីមួយៗស្មើ ៣៦៨០០ ស្វ៏ឡាត់ ។
បើស្វ៏ឡាត់យ៉ាម៉ាអុស់មានគ្នា ១០ នាក់ រ៉ក់អាត់នីមួយៗស្មើ ៧២៨០០ ស្វ៏ឡាត់ ។
បើស្វ៏ឡាត់យ៉ាម៉ាអុស់មានគ្នាលើសពី ១០ នាក់ រ៉ក់អាត់នីមួយៗមិនអាចកាត់ថ្លៃបានទេ មានតែអល់ឡោះហ្វ៍ទេដែលអាចរាប់អស់ ។

មិនបាច់ចងចាំអ្វីដែលនៅខាងលើនេះទេ គ្រាន់តែចង់ឲ្យដឹងថាស្វ៏ឡាត់យ៉ាម៉ាអុស់ និងស្វ៏ឡាត់ម្នាក់ឯងខុសគ្នាប៉ុណ្ណា ។ គេឃើញហើយថាបើមានគ្នាលើសពី ១០ នាក់ ក្នុងស្វ៏ឡាត់យ៉ាម៉ាអុស់ រង្វាន់របស់រ៉ក់អាត់នីមួយៗមិនមានអ្នកណាអាចកាត់ថ្លៃបានទេ ក្រៅពីអល់ឡោះហ្វ៍ ។

**ពាក្យបច្ចេកទេស**

**អ៊ីម៉ាំ**=អ្នកនាំមុខស្វ៏ឡាត់ ។
**ម៉ាក់មុម** (مأموم)=អ្នកស្វ៏ឡាត់ខាងក្រោយអីម៉ាំ ។
**ហ្វ៊ូរ៉ដា** (فردى)=ស្វ៏ឡាត់តែឯង ។

**មេរៀនទី ២**

# ស្វ៏ឡាត្វ៉ - ស្វ៏ឡាត្វ៉យ៉ាម៉ាអ៊ាស្វ៉(២)

**ខ-សារសំខាន់របស់ស្វ៏ឡាត្វ៉យ៉ាម៉ាអ៊ាស្វ៉**

គេអាចយល់សារសំខាន់របស់ស្វ៏ឡាត្វ៉យ៉ាម៉ាអ៊ាស្វ៉បានដូចតទៅ គឺៈ

១. ដូចដែលបានអធិប្បាយខាងលើរួចមកហើយ រង្វាន់របស់ស្វ៏ឡាត្វ៉យ៉ាម៉ាអ៊ាស្វ៉គ្មានព្រំដែនទេ ។

២. ប្រសើរឲ្យចាំបន្តិចដើម្បីចូលរួមក្នុងស្វ៏ឡាត្វ៉យ៉ាម៉ាអ៊ាស្វ៉ ជាជាងស្វ៏ឡាត្វ៉ម្នាក់ឯងនៅដើមពេល (អាវ៉ាល់ វ៉ាក់ទូ) ។

៣. បើអ្នកបានស្វ៏ឡាត្វ៉វ៉ាយ៉ីបហ្វ៉ើរ៉ដ្វារួចហើយ ហើយបានឃើញគេស្វ៏ឡាត្វ៉យ៉ាម៉ាអ៊ាស្វ៉ អ្នកនោះអាចមកចូលរួមក្នុងស្វ៏ឡាត្វ៉យ៉ាម៉ាអ៊ាស្វ៉បាន ហើយបំពេញស្វ៏ឡាត្វ៉ដដែលសាថ្មីបាន ។ អ្នកនោះនឹងទទួលបាននូវរង្វាន់ច្រើនដោយធ្វើបែបនេះ ។

៤. បើឪពុកនិងម្ដាយដាក់បញ្ជាឲ្យកូនប្រុសខ្លួនបំពេញស្វ៏ឡាត្វ៉យ៉ាម៉ាអ៊ាស្វ៉ បើកូនប្រុសនោះខ្លាចឪពុកម្ដាយទាស់ចិត្តបើខ្លួនមិនធ្វើតាមទេនោះ វ៉ាយ៉ីបសម្រាប់កូនប្រុសនោះត្រូវបំពេញស្វ៏ឡាត្វ៉យ៉ាម៉ាអ៊ាស្វ៉ ។

៥. អ្នកណាដែលមិនចេះថាឬសូត្រត្រឹមត្រូវទេ អ្នកនោះគប្បីបំពេញស្វ៏ឡាត្វ៉យ៉ាម៉ាអ៊ាស្វ៉ ដើម្បីសិក្សារបៀបសូត្រឲ្យបានត្រឹមត្រូវ ។

៦. យោលតាអ្នកប្រាជ្ញាមួយចំនួនខាងសាសនា គេមិនអាចបំពេញស្វ៏ឡាត្វ៉យ៉ាម៉ាអ៊ាស្វ៉ហ្វ៉ើរ៉ដ្វាបានទេ ពេលដែលគេកំពុងបំពេញស្វ៏ឡាត្វ៉យ៉ាម៉ាអ៊ាស្វ៉ ។

៧. បើគេមិនអាចចាត់ទុកអ៊ីម៉ាំជា "អាត្ទិល (គឺត្រឹមត្រូវ)" បានទេ ហើយបានចូលមកក្នុងម៉ាស់យ៊ីដហើយ គេត្រូវបំពេញស្វ៍ឡាត់ហ្វ៊ៀដ្ឋាក្នុងចន្លោះអាស្ទាន និងអ៊ីក៏ម៉ាត់ ឬត្រូវរង់ចាំឲ្យស្វ៍ឡាត់យ៉ាម៉ាអាស់ចប់ ជាការគោរព ហើយទើបបំពេញស្វ៍ឡាត់ហ្វ៊ៀដ្ឋា ។

៨. ថៃមរុកនដោយចេតនាក្តី ដោយអចេតនាក្តី ធ្វើឲ្យស្វ៍ឡាត់មោឃៈ តែសម្រាប់ស្វ៍ឡាត់យ៉ាម៉ាអាស់ ការបន្ថែមបែបនេះត្រូវអនុលោមដោយសារតែស្វ៍ឡាត់នេះសំខាន់ពេក (នឹងអធិប្បាយលំអិតនៅខាងមុខ) ។

## គ-ចូលរួមក្នុងស្វ៍ឡាត់យ៉ាម៉ាអាស់ដូចម្តេច

១. នៅក្នុងរ៉ក់អាត់ទី ១ និង ទី ២ របស់ស្វ៍ឡាត់យ៉ាម៉ាអាស់ យកល្អឲ្យចូលរួមក្នុងពេលដែលអ៊ីម៉ាំកំពុងតែសូត្រស៊ូរ៉ោះត៏ទីមួយ ឬស៊ូរ៉ោះត៏ទីពីរ ឬកំពុងតែរុគុអ៍ ។

២. នៅក្នុងរ៉ក់អាត់ទី ៣ និង ទី ៤ របស់ស្វ៍ឡាត់យ៉ាម៉ាអាស់ យកល្អឲ្យចូលរួមក្នុងពេលដែលអ៊ីម៉ាំចុះរុគុអ៍ ។ បើអ្នកចូលរួមក្នុងពេលគ៊ីយ៉ាម ក្នុងពេលដែលអ៊ីម៉ាំកំពុងតែសូត្រស្វាត់ៗ "តាស់ប៊ីហ្វាត់ អារបាអាស់" អ្នកចាំបាច់ត្រូវសូត្រយ៉ាងហោចណាស់ស៊ូរ៉ោះត៏អាល់-ហ្វាំដ៏ ហើយ បើអ្នកមិនអាចសូត្រស៊ូរ៉ោះត៏អាល់-ហ្វាំដ៏ចប់ទេ ហើយអ៊ីម៉ាំងើបឡើងពីរុគុអ៍វិញ អ្នកចាំបាច់ត្រូវប្តូរនៀតជាស្វ៍ឡាត់ហ្វ៊ៀដ្ឋាវិញ ហើយបំពេញស្វ៍ឡាត់ឲ្យគ្រប់ជាស្វ៍ឡាត់ហ្វ៊ៀដ្ឋា ។

៣. បើអ្នកចូលមកក្នុងម៉ាស់យ៊ីដ ហើយមិនដឹងថាគេកំពុងតែបំពេញរ៉ក់អាត់ណាទេ អ្នកត្រូវរង់ចាំទាល់តែអ៊ីម៉ាំចុះទៅរុគុអ៍ ។

៤. បើអ្នកចូលមកក្នុងម៉ាស់យ៊ីដ ហើយដឹងថាគេកំពុងតែស៊ូយ៉ូដរ៉ក់អាត់ចុងក្រោយ ហើយអ្នកចង់ចូលរួមក្នុងស្វ៍ឡាត់យ៉ាម៉ាអាស់ដើម្បីទទួលបាននូវស្វាវ៉ាប់ អ្នកត្រូវនៀត ហើយតាក់ប៊ីរ៉ទុល អ៊ិះហ្វ៉ារ៉ម ហើយចូលរួមក្នុងស្វ៍ឡាត់យ៉ាម៉ាអាស់ត្រង់ស៊ូយ៉ូដ។ បន្ទាប់មក ពេលអ៊ីម៉ាំតាស្វាស់ហ្វ៊ូដចប់ហើយឲ្យសាឡាមចប់ហើយ អ្នក

ត្រូវងើបឡើងវិញ ចាប់ផ្ដើមសូត្រស្វរ៉ោះត៍ទីមួយនិងស្វរ៉ោះត៍ទីពីរ ។

ក) ក្នុងករណីនេះ ក្នុងពេលតាស្ហាស្វហ៊្វុដនិងសាឡាម អ្នកត្រូវលើកជង្គង់ពីដី ច្រត់ដៃលើដី ចាំឲ្យអ៊ីមុាំសូត្រសាឡាមចប់ ។

ខ) បើអ្នកចូលរួមត្រង់រ៉ក់អាត់ទី២ ទី៣ ឬ ទី៤ ត្រូវលើកជង្គង់ក្នុងពេល តាស្ហាស្វហ៊្វុដនិងសាឡាមដែរ ។

៥. ម៉ាក់មូមីន (ពួកម៉ាក់មុម) ដែលស្វឡាត់នៅខាងក្រោយអ៊ីមុាំត្រូវសូត្រស្ទីករ៍ទាំងអស់ លើកលែងតែស្វរ៉ោះត៍ទី១និងស្វរ៉ោះត៍ទី២ក្នុងរ៉ក់អាត់ទី១និងទី២ ។

៦. អ្នកចាំបាច់ត្រូវសូត្រស្ងាត់ៗទាំងអស់នូវអ្វីដែលត្រូវសូត្រវ៉ាយ៉ិបឬស្វណាត់ តាមក្រោយអ៊ីមុាំ មិនឲ្យសូត្រមុនអ៊ីមុាំដោយចេតនាទេ ព្រោះវាធ្វើស្វឡាត់អ្នកមោឃៈ ។

## ឃ-លក្ខខណ្ឌរបស់ស្វឡាត់យ៉ាម៉ាអាស់

១. ជួរទីមួយ បន្ទាប់អ៊ីមុាំ ស្វណាត់ឲ្យមនុស្សចាស់និងអ្នកចេះដឹងនៅក្នុងជួរនេះ ។

២. អ្នកដំណើរដែលបំពេញស្វឡាត់ កូស្វរ៍ (ស្វឡាត់អ្នកដំណើរ) ឬអ្នកដែលមានបញ្ហាដើរខ្យល់ មិនគប្បីនៅជួរទី១ទេ ។

៣. ត្រូវឈរក្នុងជួរជិតគ្នា ស្មាទល់ស្មា ។ ម៉ាក់រុះហ្វបើចាប់ផ្ដើមតម្រៀបជួរទី២នៅពេលដែលមាននៅសល់កន្លែងក្នុងជួរទី១ ។

៤. មានតែស្វឡាត់វ៉ាយ៉ិបទេ អាដ្ហាអ៍ ឬ ក៏ដ្ហ៍ ដែលអាចធ្វើបានជាស្វឡាត់យ៉ាម៉ាអាស់ ។ ស្វឡាត់ស្វណាត់មិនអាចធ្វើក្នុងស្វឡាត់យ៉ាម៉ាអាស់បានទេ លើកលែងតែស្វឡាទុល អ៊ីដ្ហៃន៍ (ស្វឡាត់អ៊ីដទាំងពីរ) និងស្វឡាត់អ៊ីសទីសក៏អ៍ ។

៥. ពេលអ៊ីមុាំសូត្រតាក់ប៊ីរ៉ទុល អិះហ្ររ៉ម ប្រសើរឲ្យជួរទីពីរថាតាក់បៀរក្រោយជួរទី

មួយ ។

៦. បើមានស្ត្រីចូលរួមក្នុងស្វឡាត្ជុំយ៉ាម៉ាអាត់ ត្រូវឲ្យនៅក្រោយប្រុសៗ (បើពុំមានរាំងនន) ។ បើមានរាំងននរវាងប្រុសៗនិងស្រីៗ ស្រីៗអាចនៅស្មើប្រុសៗបាន ។

៧. អ៊ីម៉ាំយ៉ាម៉ាអាត់ប្រុសនិងអ៊ីម៉ាំយ៉ាម៉ាអាត់ស្រីខុសគ្នាត្រង់ ៖

ក) អ៊ីម៉ាំប្រុសអាចមានម៉ាក់មូមីនប្រុសនិងស្រី ។ អ៊ីម៉ាំស្រីមិនអាចមានម៉ាក់មូមីនប្រុសបានទេ ។

ខ) អ៊ីម៉ាំប្រុសមានម៉ាក់មូមីនឈរនៅខាងក្រោយ ។ អ៊ីម៉ាំស្រីឈរស្មើនឹងម៉ាក់មូមីនស្រីក្នុងជួរទីមួយ ។

៨. អ៊ីម៉ាំយ៉ាម៉ាអាត់មានលក្ខខណ្ឌដូចតទៅគឺ ៖

ក. បាលីក្ខ (គឺគ្រប់អាយុ) ។
ខ. អាចសូត្របានយ៉ាងត្រឹមត្រូវ (ម៉ាក្ខរីច្ចត្រឹមត្រូវ) ។
គ. ជាមុមីន - គឺ ស្ជីអាត់ អ៊ីស្នណា អាស្ជូស្វារីយ៉ាស់ (شيعة اثنا عشرية)
ឃ. អាគ្ហីល (មានសតិអារម្មណ៍គ្រប់គ្រាន់ - មិនវិកលចរិត)
ង. មានកំណើតស្របច្បាប់ ។
ច. អាឌ្ហីល (គឺត្រឹមត្រូវ - យុត្តិធម៌) ។ អ្នកដែលគេមិនស្គាល់ថាជាបុគ្គលដែលប្រព្រឹត្តបាបធំ ដែលមានចរិយាមារយាទស្របតាមច្បាប់អ៊ីស្លាម ។

**មេរៀនទី ៣**

# ណាយ៉ាសាស្ញ

**ណាយ៉ីស** គឺវត្ថុដែលត្រូវចាត់ទុកថាមិនស្អាតយោលតាមច្បាប់សាសនា(ស្ហារីអាស្ញ) ។

វត្ថុទាំងនេះមិនស្អាតដោយខ្លួនឯង ហើយធ្វើឲ្យវត្ថុផ្សេងមិនស្អាតដោយការប៉ះពាល់វា ។ វត្ថុមួយទៅជាណាយ៉ីស (គឺមិនស្អាត) ដោយការប៉ះពាល់ជាមួយណាយ៉ាសាស្ញ (តួអង្គណាយ៉ីស) ប្រសិនបើវត្ថុណាមួយនៃវត្ថុទាំងពីរទទឹកឬសើម ។ ដូច្នេះ វត្ថុណាយ៉ីសដែលស្ងួតមិនអាចធ្វើឲ្យវត្ថុផ្សេងទៅជាណាយ៉ីសបានទេ បើវត្ថុមួយនេះស្ងួតដែរ ។

មានណាយ៉ាសាស្ញពីរប្រភេទ វិធីជម្រះឲ្យបរិសុទ្ធពីណាយ៉ាសាស្ញនេះពឹងពាក់ទៅលើប្រភេទរបស់ណាយ៉ាសាស្ញនេះ ។

ក) **ហ្ហាដ្ញាស្ញ** (الحدث) គឺណាយ៉ាសាស្ញដែលទាមទារឲ្យមាននៀត(បំណង)ដើម្បីជម្រះឲ្យបរិសុទ្ធ ។ នោះគឺណាយ៉ាសាស្ញដែលគេជម្រះចេញតាមរយៈវូឌុអ៏ (وضوء) ឬ ក៊ុសល៍ (ឬ ឃ៊ូស៊្វល غسل) ។

ហ្ហាដ្ញាស្ញមានពីរប្រភេទគឺះ

១-(ហ្ហាដ្ញាស្ញធំ) ចាំបាច់ត្រូវប្រើវិធីក៊ុសល៍ (ឬ ឃ៊ូស៊្វល) ដើម្បីធ្វើឲ្យបរិសុទ្ធស្របតាមច្បាប់សាសនា ។
២-(ហ្ហាដ្ញាស្ញតូច) ចាំបាច់ត្រូវប្រើវិធីវូឌុអ៏ដើម្បីធ្វើឲ្យបរិសុទ្ធស្របតាមច្បាប់សាសនា ឧទាហរណ៍ ដេកលក់ ជាដើម ។

ខ) **ខាបាស្ញ** ណាយ៉ាសាស្ញទាំងនេះមិនចាំបាច់ឲ្យមាននៀតទេ ដើម្បីធ្វើឲ្យបរិសុទ្ធ

ស្របតាមច្បាប់សាសនា ។ ណាយ៉្ហសាស្ទទាំងនេះមានចំនួន ១០ គឺៈ

| | | | |
|---|---|---|---|
| ១. ទឹកនោម | ២. លាមក | ៣. ឈាម | ៤. ទឹកកាម |
| ៥. សាកសព | ៦. ឆ្កែ | ៧. ជ្រូក | ៨. កាហ្វៀរ |
| ៩. ស្រា | ១០. ហ្វុក្កក៏ | | |

**ទឹកនោមនិងលាមក** សត្វរស់ដែលឈាមបាញ់ (ពេលសំឡៃះ) ហើយសាច់ហ្វារ៉ាំបរិភោគ ។ ក៏ប៉ុន្តែសត្វដែលសាច់ហ្វារទ្បាល់ទៅជាហ្វារ៉ាំបើវាស៊ីសំរាម ដូច្នេះទឹកនោមនិងលាមកវាទៅជាណាយ៉ិស ។ ឧទាហរណ៍ បើគោធ្លាប់តែស៊ីសំរាមមនុស្ស ទឹកនោមនិងលាមកវាទៅជាណាយ៉ិស ។ បានសេចក្តីថា បើអ្នកចង់ដឹងថាតើទឹកនោម និង/ឬ លាមកណាយ៉ិសឬទេ អ្នកត្រូវពឹងផ្អែកលើសំណួរពីរខាងក្រោមនេះគឺៈ

១-តើឈាមសត្វនោះចេញមកដោយបាញ់ទេ ?

២-តើសាច់សត្វនោះហ្វារ៉ាំទេ ?

**ឈាម** សត្វដែលឈាមបាញ់ (ពេលសំឡៃះ) ទោះបីសាច់វាហ្វារទ្បាល់ឬមិនហ្វារទ្បាល់ក៏ដោយ ។

**សាកសព** របស់សត្វទាំងឡាយណាដែលឈាមបាញ់ ។ ក៏ប៉ុន្តែសាកសពសត្វដែលសាច់ហ្វារទ្បាល់ហើយត្រូវសំឡៃះស្របតាមច្បាប់សាសនានោះ ជាសាកសពបរិសុទ្ធ ។ សាកសពមុស្លីមក្រោយពីបានលាងសម្អាតស្របតាមច្បាប់សាសនាហើយ ទៅជាបរិសុទ្ធ ។ ប៉ែកនៃរូបកាយដែលមិនមានជីវិត ដូចជា សក់ ក្រចក ឆ្អឹង ធ្មេញ ។ល ។ មិនណាយ៉ិសទេ ។

**ឆ្កែនិងជ្រូក** ដែលរស់នៅលើផែនដីជាណាយ៉ិស ។ តាមន័យទូលាយ រោមវា ឆ្អឹងវា ធ្មេញវា និងញើសវា ជាណាយ៉ិស ។

**កាហ្វៀរ** កាហ្វៀរគឺបុគ្គលដែលមិនជឿអល់ឡោះហ្វ៍និងថ្ងៃជំនុំជម្រះទេ ។ មុស្ហ៍រីក (مشرك) គឺបុគ្គលដែលជឿថាអល់ឡោះហ្វ៍មានដៃគូច្រើន ដូច្នេះបុគ្គលនេះត្រូវចាត់ទុក

ជាណាយីសដូចបុគ្គលកាហ្វៀរដែរ ។ ពួក "អាស្ហ់លី គីតាប (اهل كتاب)" ដែលបដិសេធព្រះសាស្តា មូហាំម៉ាដ់ មុសតាហ្វាﷺ ជាណាយីសដែរ ។ រូបកាយមនុស្សបែបនេះជាណាយីស រាប់បញ្ចូលសក់ ក្រចក ធ្មេញនិងញើសពួកគេនោះផងដែរ ។

**ស្រា** : ភេសជ្ជៈស្រវឹងនេះជាណាយីស ។

**ហ្វ៊ុក្កុំ** : នេះគឺស្រាបៀយ៉ែរ ជាណាយីស ។

## មេរៀនទី ៤

# គុសល៍ (ឬ គុស៊្ហូល)

គុសល៍ (ឬ គុស៊្ហូល غسل) ជាពាក្យអារ៉ាប់ មានន័យថា "ងូតទឹកដើម្បីលាងបន្សុទ្ធខ្លួន" ។ ច្បាប់អ៊ីស្លាម ស្ហារីអាុស្ញ (شريعة) បានដាក់គុសល៍ជាបង្គាប់វ៉ាយ៊ីបសម្រាប់ស្ថានភាពមួយចំនួន ជាស៊ូណាត់សម្រាប់ស្ថានភាពមួយឯទៀត ។ ក្នុងករណីគុសល៍ស៊ូណាត់ មានស្ហារ៉ាប់ច្រើន ។ របៀបប្រតិបត្តិគុសល៍មានចែងនៅក្នុងច្បាប់ស្ហារីអាុស្ញ ហើយមិនអាចធ្វើតាមរបៀបផ្សេង ពីរបៀបដែលច្បាប់ស្ហារីអាុស្ញបានចែងនោះជាដាច់ខាត ។

**ប្រភេទគុសល៍** បានអធិប្បាយខាងលើហើយ គុសល៍អាចជាវ៉ាយ៊ីប ឬ ជាស៊ូណាត់ ។

មាន ៧ គុសល៍វ៉ាយ៊ីប មានដូចជា គុសល៍ ម៉ាយិត, គុសល៍ ម៉ាស់ ម៉ាយិត, គុសល៍ ណាស៊្ញរ៍, គុសល៍ ក៏ស៊ីម៉ា(قسم), គុសល៍ អាហ្វាដ្ញ(عهد) ។ល ។

មានច្រើនគុសល៍ ស៊ូណាត់ ។ គុសល៍ ស៊ូណាត់មួយ ក្នុងចំណោមគុសល៍ ស៊ូណាត់ដែលសំខាន់បំផុតគឺ គុសល៍ យ៉ុមអាុត្ញ(ថ្ងៃសុក្រ) ដែលម៉ាក់ស៊្ហូមីនយើងﷺបានផ្ដែផ្ដាំ ។ គុសល៍ ស៊ូណាត់មួយទៀតគឺ គុសល៍ អ៊ីដ្ញ (ថ្ងៃបុណ្យ អ៊ីឌុល ហ្វិត្តរី (عيد الفطر) ឬ អ៊ីឌុល អាដ្ហូហ្ហា (عيد الأضحى) ។

### លក្ខខណ្ឌរបស់គុសល៍

ក) ទឹកគុសល៍ត្រូវតែបរិសុទ្ធ មុត្ហឡាក់ (مطلق) និង មូបាស៊្ញ ។

ខ) កន្លែងដែលយកទឹកគុសល៍ត្រូវតែមូបាស៊្ញ ។ សម្ភារៈប្រើសម្រាប់យកទឹកគុសល៍ត្រូវមូបាស៊្ញដែរ មិនធ្វើអំពីមាស ឬប្រាក់ទេ ។

គ) មុនយកទឹកគុ្មសល់ រូបកាយរបស់អ្នកត្រូវស្អាតពីណាយ៉ីសគ្រប់ប្រភេទជាមុនសិន ដូចជា ទឹកកាម ឬ ឈាមរដូវខែ(حيض) ។

ឃ) គុ្មសល់ត្រូវប្រតិបត្តិទៅក្នុងបំណងគួរបាតាន់ អ៊ីឡុលឡោះហ្វ ពោលគឺ ក្នុងបំណងទៅរកអល់ឡោះហ្វ៍ﷻនិងក្នុងបំណងគោរពតាមព្រះបញ្ជាព្រះអង្គﷻ ។

ង) គុ្មសល់ត្រូវប្រតិបត្តិដោយខ្លួនឯង មិនពឹងអ្នកដទៃទេ លើកលែងតែមានជម្ងឺ ។

ច) ការប្រើទឹកដើម្បីបំពេញគុ្មសល់ មិនត្រូវធ្វើឲ្យមានគ្រោះថ្នាក់ដល់សុខភាពទេ ។

ឆ) ត្រូវយកចេញនូវសារធាតុខ្លាញ់ ឬ វត្ថុកខ្វក់ដទៃទៀតដែលឃាត់ទឹកមិនឲ្យទៅដល់រូបកាយ ។ ដូច្នេះ ប្រេង ថ្នាំលាបសក់ឲ្យរឹង ថ្នាំលាបក្រចក ក្រមួនលាបបបូរមាត់ ។ល ។ ចាំបាច់ត្រូវយកវាចេញឲ្យអស់មុនយកទឹកគុ្មសល់ ។

## របៀបយកទឹកគុ្មសល់

១. **គុ្មសល់ តារទីប៊ី** (الغسل الترتيبى) គឺគុ្មសល់ដែលប្រព្រឹត្តទៅតាមលំដាប់ ។ បន្ទាប់ពីនៀតរួច លាងក្បាលរហូតដល់ក ។ បន្ទាប់មក ត្រូវលាងប៉ែករូបកាយដែលនៅសល់ ឬ លាងដំបូងប៉ែកខាងស្តាំទាំងអស់របស់ខ្លួន រាប់បញ្ចូលខ្មាសបន្ទាប់មកលាងប៉ែកខាងឆ្វេងទាំងអស់របស់ខ្លួន (ខ្មាសដែរ) ។

២. **គុ្មសល់ អៀរទីម៉ាស៊ី** (غسل الارتماسى) គឺគុ្មសល់ដែលធ្វើតែមួយលើក ដោយមុជក្នុងទឹក ។ អាចប្រព្រឹត្តទៅបានក្នុងទន្លេ ក្នុងស្ទឹង ក្នុងអាងហែលទឹក ឬក្នុងអាងទឹកធំលើសពីមួយ "គូរ" ។ ក្រោយពីនៀតរួច មុជក្នុងទឹកទាំងខ្លួនតែម្តង ។

**មេរៀនទី ៥**

# បែបបទក្នុងការបន្ទោបង់

**ច្បាប់បន្ទោបង់**

១. កន្លែងអង្គុយដើម្បីបត់ជើងតូច ឬ បត់ជើងធំចាំបាច់ត្រូវឲ្យខ្មាសកំបាំង(ពីភ្នែកអ្នកដទៃ) ។

២. ឈានចូលក្នុងបង្គន់ដោយជើងឆ្វេង ហើយច្រត់លើជើងឆ្វេងដើម្បីអង្គុយ ។

៣. ហាមបត់ជើងតូចឬបត់ជើងធំនៅកន្លែងដូចតទៅគឺៈ

-លើកន្លែងអ្នកដទៃដោយឥតបានទទួលការអនុញ្ញាតពីម្ចាស់កន្លែង ។

-លើកន្លែងដែលទុកសម្រាប់តែក្រុមណាមួយ (សម្រាប់បុគ្គលដែលមិនមែនជាសមាជិករបស់ក្រុមនេះ) ។

-លើផ្នូរមុស្លីម និង លើកន្លែងសក្ការបូជា (ម៉ាស់យ៉ិដ្ធ, អ៊ីមុាំបារ៉...)

៤. ហាមបែរខ្នងឬបែរមុខដាក់គិ្លបឡាត់ពេលបត់ជើងតូចឬបត់ជើងធំ ។

៥. ក្រោយពីបត់ជើងតូចរួចត្រូវលាងពីរដង (យកល្អបីដង) ។

៦. ក្រោយពីបានបត់ជើងធំរួចត្រូវលាងដោយទឹក ពុំនោះទេ អាចជូតបានជាមួយក្រដាសស្អាត (ត៊ិហ្សៀវ) ហើយស្ងួត ។ ត្រូវប្រើបីចំណែកក្រដាសដាច់ឡែកគ្នា ។ ប្រសើរឲ្យលាងជាមួយទឹក ក្រោយពីបានបត់ជើងធំរួច ក៏ប៉ុន្តែអាចប្រើក្រដាសនិងទឹកបាន ។

៧. ហាមប្រើវត្ថុជាទីសក្ការបូជាជូត (ឬកិត) ក្រោយពីបានបត់ជើងធំរួច ដូចជា "ខាកេ ស្ទីហ្វាអ៊ុ" (គឺដីការបាឡាអ៊ុ) ក្រដាសមានព្រះនាមអល់ឡោះហ្ជ៉ ព្រះនាម

ម៉ាក់ស៊្ទមមីន عليه السلام ជាដើម ។

៨. និយាយនៅក្នុងបង្គន់ជាម៉ាក់រុះហ្វ ។

៩. ហាមបត់ជើងតូចលើកន្លែងដូចតទៅ ដោយមានលក្ខខណ្ឌ គឺ៖
-ពេលឈរ (បត់ជើងតូចឈរមានទណ្ឌកម្មធ្ងន់ក្រោយពីស្លាប់) ។
-កន្លែងដែលខ្យាយប៉ះអ្នកដទៃ ។
-ក្នុង(ឬដាក់)ទឹក ។
-ដាក់រន្ធ(ឬរូង) (រន្ធក្នុងដីរបស់សត្វ) ។
-លើផ្លូវ ។
-ជិតជញ្ជាំងម៉ាស់យ៉ីដ្ឋ ។
-នៅទីបរិវេណផ្ទះ ។
-ក្រោមដើមឈើហូបផ្លែ ។
-កន្លែងដែលអាចធ្វើឲ្យមនុស្សទើសទាល់ចិត្ត ។

**មេរៀនទី ៦**

# មូតោះហ្ហ៊ីរ៉ត់(១)

មាន ១២ មូតោះហ្ហ៊ីរ៉ត(مطهرات)ដែលធ្វើឲ្យវត្ថុត្រូវណាយ៉ីសបរិសុទ្ធស្អាតបាន គឺៈ

| | |
|---|---|
| ១. ទឹក | ២. ដី |
| ៣. ថ្ងៃ | ៤. អ៊ីសទីហ្ហាឡាស្ហ(إستحالة) |
| ៥. អ៊ីនគ្ហ៊ីឡាប់ | ៦. អ៊ីនទីក្វាល់(إنتقال) |
| ៧. អ៊ីស្លាម | ៨. តាបាអ៊ីយ៉ាស្ហ(تبعية) |
| ៩. ស្ហាវ៉ាល់ អាល់-អ៊ែន៍ | ១០. ក៊ុយ់បាត់ អាល់-មុស្លីម |
| ១១. អ៊ីសទីបរ៉អ៊ុ(استبراء) | ១២. សំណល់ឈាមក្រោយពីសំឡែះ |

**១. ទឹក**

មានទឹក ២ ប្រភេទគឺៈ

ទឹកបរិសុទ្ធ(មុត្លឡាក្ហ់ المطلق) - គឺទឹកដែលមិនបានផ្លាស់ប្តូរសោះ ទាំងព័ណ៌ ទាំងក្លិន និងទាំងរសជាតិ ។ ទឹកមុតឡាក្ហ់អាចធ្វើឲ្យវត្ថុត្រូវណាយ៉ីសទៅជាបរិសុទ្ធបាន ។

ទឹកលាយ ឬ ទឹកល្បាយ (مضاف) - ទឹកល្បាយមិនអាចធ្វើឲ្យវត្ថុត្រូវណាយ៉ីសទៅជាបរិសុទ្ធបានទេ ។ វាទៅជាណាយ៉ីសបើវាប៉ះណាយ៉ីស ។

ទឹកខាងក្រោមនេះជាទឹកមុត្លឡាក្ហ់ គឺៈ
-ទឹកភ្លៀង ។
-ទឹកហូរ (រាប់បញ្ចូលទឹកម៉ាស៊ីនដែរ) ។
-ទឹកអណ្តូង ។
-ទឹកនឹង (ទឹកក្នុងអាង, ធុង...) ដែលមានចំនួនលើសពីមួយ "គូរ" ។ (អាប់ កាស្ស៊ៀរ)

-ទឹកនឹង (ទឹកក្នុងអាង, ធុង...) ដែលមានចំនួនតិចជាងមួយ "គូរ" ។ (អាប់ ក៏្សលីល)

ទឹកមួយ "គូរ" គឺទឹកក្នុងអាងឬធុងទំហំលើសពី ៣៨៤ លីត្រ (អាងទឹកបួនជ្រុងដែលមានប៉ែកខាងប្រវែង ៧២,៦៨ សង់ទីម៉ែត្រ ស្មើនឹង ៧ តឹក) ។

ទឹកតិចជាងមួយ "គូរ" ទៅជាណាយ៉ីសបើវាប៉ះណាយ៉ីស ។

**ការប្រើប្រាស់ទឹកក្នុងការជម្រះបន្សុទ្ធ**

| **វត្ថុត្រូវណាយ៉ីសដែលត្រូវជម្រះបន្សុទ្ធ** | **ជម្រះបន្សុទ្ធជាមួយទឹកដែលមានចំនួនលើសពីមួយ "គូរ"** | **ជម្រះបន្សុទ្ធជាមួយទឹកដែលមានចំនួនតិចជាងមួយ "គូរ"** |
|---|---|---|
| សំលៀកបំពាក់ណាយ៉ីសដោយសារទឹកនោម | ១ ដង (យកល្អ ២ ដង) | ២ ដង (យកល្អ ៣ ដង) |
| សំលៀកបំពាក់ណាយ៉ីសដោយសារអ្វីផ្សេងពីទឹកនោម | ១ ដង | ២ ដង |
| ខ្លួនណាយ៉ីសដោយសារទឹកនោម | ១ ដង | ២ ដង |
| ខ្លួនណាយ៉ីសដោយសារអ្វីផ្សេងពីទឹកនោម | ១ ដង | ១ ដង |
| គ្រឿងប្រើប្រាស់សម្រាប់ផ្ទះបាយត្រូវណាយ៉ីស | ១ ដង | ៣ ដង |
| គ្រឿងប្រើប្រាស់សម្រាប់ផ្ទះបាយដែលត្រូវជ្រូកលិទ្ធ ឬ កណ្តុរស្លាប់លើ | ៧ ដង | ៧ ដង |
| គ្រឿងប្រើប្រាស់សម្រាប់ផ្ទះបាយដែលណាយ៉ីសដោយសារស្រា | ៣ ដង | ៣ ដង |
| គ្រឿងប្រើប្រាស់សម្រាប់ | ដុសជាមួយដីទទឹក ហើយ | ដុសជាមួយដីទទឹក |

| | | |
|---|---|---|
| ផ្ទះបាយដែលត្រូវឆ្កែលិទ្ធ ឬ ទឹកមាត់ឆ្កែធ្លាក់លើ | លាងទឹក ៣ ដង | ហើយ លាងទឹក ៣ ដង |

លើសពីបរិសុទ្ធនិងមុត្ទឡាក់ (គឺបរិសុទ្ធតាំងពីកំណើត) ទឹកមិនត្រូវឲ្យក្លាយទៅជាមូជ្ជហ៊្ញ (ប្តូរភាពដោយការប៉ះពាល់) ទេនៅពេលដែលវាធ្វើឲ្យវត្ថុត្រូវណាយ៉ីសបរិសុទ្ធ ។ ដូច្នេះ ដើម្បីលាងជាមួយទឹក ចាំបាច់ត្រូវយកណាយ៉ីសចេញពីវត្ថុត្រូវណាយ៉ីសសិនដោយការលាង ។ ត្រូវពូតសំលៀកបំពាក់ក្រោយពីបោករួច ។

**មេរៀនទី ៧**

# មូតោះហ្ហ៊ីរ៉ាត់(២)

**២. ដី**

បើស្បែកជើងឬបាតជើងទៅជាណាយ៉ីសដោយប៉ះណាយ៉ីសពេលដើរ វានឹងបរិសុទ្ធវិញបានដោយដើរមួយសន្ទុះលើដីស្អាតហើយស្ងួតទាល់តែណាយ៉ីសបាត់អស់ ។

**៣. ថ្ងៃ**

ថ្ងៃអាចធ្វើឲ្យវត្ថុទាំងនោះដែលគេមិនអាចប្តូរកន្លែងវាបាន ទៅជាបរិសុទ្ធវិញបាន ឧទាហរណ៍ ជញ្ជាំង ផ្លូវ ផ្ទៃដី ទ្វារនិងបង្អួច ។ល ។ ពេលណាយ៉ីសត្រូវយកចេញពីវត្ថុទាំងនេះ ហើយធ្វើឲ្យកន្លែងណាយ៉ីសទទឹក កាំរស្មីរបស់ថ្ងៃនឹងធ្វើឲ្យវត្ថុទាំងនេះបរិសុទ្ធ ។

**៤. អ៊ីសទីហ្ហាឡាស់**(إستحالة ការផ្លាស់ប្តូរធាតុគីមី ឬ ធាតុអណូឬម៉ូឡេគូល ពោលគឺ ប្រែរូប)

នេះគឺករណីដែលវត្ថុណាយ៉ីសផ្លាស់ប្តូរទាំងស្រុង ដល់ថ្នាក់វត្ថុធាតុដើមរបស់វាបាត់អស់តែម្តង ។ ឧទាហរណ៍ ដំបងណាយ៉ីសឆេះទៅជាផេះ ឬឆ្កែងាប់រលួយហើយទៅជាធូលី ។

**៥. អ៊ីនគ្វីឡាប់**

គឺការផ្លាស់ប្តូរគុណភាពរបស់តួអង្គណាយ៉ីស (ខុសពីការផ្លាស់ប្តូរវត្ថុធាតុដើម) ។ ឧទាហរណ៍ ពេលដែលស្រាទៅជាទឹកខ្មេះ ដោយសារការហួតចំហាយអស់ពីរភាគបីនៃចំនួនដើមរបស់វា ។

**៦. អ៊ីនទីក្វល់**(إنتقال)

គឺការផ្លាស់ប្តូកន្លែងក្នុងករណីខ្លះ ។ ពេលតួអង្គណាយ៉ីសលាយជាមួយវត្ថុមួយទៀត

ដែលបរិសុទ្ធ វត្ថុនោះទៅជាបរិសុទ្ធ ។ ឧទាហរណ៍ មូសបឺតឈាមមនុស្ស (ដែលណាយ៉ីស) បន្ទាប់ពីមួយរយៈពេល ឈាមនេះទៅជាឈាមរបស់មូសនេះ ហើយឈាមមូសនេះបរិសុទ្ធ ។

**៧. អ៊ីស្លាម**

ពេលអ្នកឥតជំនឿមានសទ្ធាចំពោះអល់ឡោះហ្វ៍ﷻតែមួយគត់ និងជឿព្រះសាស្ដាមូហាំម៉ាដ់ﷺ អ្នកនេះទៅជាបរិសុទ្ធ ។

**៨. តាបាអ៊ីយ៉ាស់**(تبعية)

គឺករណីដែលវត្ថុណាយ៉ីសទៅបរិសុទ្ធតាមគ្នា (ឬដោយស្វ័យប្រវត្ត) ។ ឧទាហរណ៍៖

ក) ពេលបុគ្គលកាហ្វៀរទៅជាមុស្លីម បុគ្គលនោះទៅជាបរិសុទ្ធ ។ កូនៗរបស់អ្នកនោះ(ដែលមិនទាន់បាលិក្ គឺមិនគ្រប់អាយុ) ទៅជាបរិសុទ្ធជាស្វ័យប្រវត្ត ។

ខ) ពេលអណ្ដូងទឹកត្រូវណាយ៉ីស គេធ្វើឲ្យវាទៅជាបរិសុទ្ធវិញដោយយោងទឹកចេញមួយចំនួន ជញ្ជាំងអណ្ដូងទឹកនេះ ខ្សែរវានិងធុងដែលគេប្រើសម្រាប់យោងទឹកទៅជាបរិសុទ្ធដែរជាស្វ័យប្រវត្ត ។

គ) ពេលគេលាងវត្ថុណាយ៉ីស ដំបូងដៃយើងទៅជាណាយ៉ីសដោយសារប៉ះពាល់ បន្ទាប់មកវាទៅជាបរិសុទ្ធព្រមគ្នានឹងវត្ថុដែលគេលាងដែរជាស្វ័យប្រវត្ត ។

ឃ) ពេលស្រាក្លាយទៅជាទឹកខ្មេះ ហើយទៅជាបរិសុទ្ធ របស់ដែលគេប្រើសម្រាប់ដាក់វា (គឺឆ្នាំង) នោះទៅជាបរិសុទ្ធដែរ ។

ង) គ្រែស្នែងម៉ាយិតដែលធ្វើអំពីឈើឬស៊ីម៉ង់ត៍ដែលដាក់ម៉ាយិត ព្រមទាំងក្រណាត់សម្រាប់គ្របខ្មាស់ម៉ាយិត ទៅជាបរិសុទ្ធព្រមនឹងសាកសពដែលត្រូវផ្ងូតទឹកគុសល៍ ម៉ាយិតឲ្យនោះដែរ ។

**៩. ស៊ាវ៉ាល់ អាល់-អ៊ៃន៍ (យកណាយ៉ីសចេញ)**

បើមានណាយ៉ីសនៅលើខ្លួនសត្វ ខ្លួនសត្វនោះស្អាតវិញបើគេយកណាយ៉ីសនោះចេញ ។ មិនចាំបាច់លាងវាទេ ។ ដូចគ្នាដែរ បើមានឈាមនៅក្នុងមាត់ឬនៅលើច្រមុះ ហើយគេបានយកវាចេញ កន្លែងនោះទៅជាបរិសុទ្ធវិញ ។

**១០. កុយ់បាត់ អាល់-មុស្លីម (បាត់ខ្លួនមុស្លីម)**

បើអ្នកដឹងថាសំលៀកបំពាក់របស់មុស្លីមម្នាក់ ដែលស្របតាមច្បាប់ស្ហារីអាស៊ុ ទៅជាណាយ៉ីស បន្ទាប់មកមុស្លីមនេះបានកំបាំងពីភ្នែកអ្នកអស់រយៈពេលយូរបន្តិចដែលគ្រប់គ្រាន់សម្រាប់ធ្វើឲ្យសំលៀកបំពាក់គេទៅជាបរិសុទ្ធបាន ។ ក្រោយមក អ្នកបានជួបគេម្តងទៀតជាមួយសំលៀកបំពាក់ដដែល អ្នកត្រូវគិតថាគាត់បានធ្វើឲ្យសំលៀកបំពាក់គាត់បរិសុទ្ធហើយ ។

**១១. អុីសទីបរ៉ អ៊ុ** (استبراء **បង្ខាំង**)

សត្វហ្វាឡាល់ ដូចជា គោ ចៀម មាន់ ទៅជាណាយ៉ីសបើវាស៊ីលាមកមនុស្ស ។ គេអាចធ្វើឲ្យវាទៅជាបរិសុទ្ធវិញបានដោយបង្ខាំងវាឆ្ងាយពីលាមកនោះ ហើយឲ្យវាស៊ីរបស់បរិសុទ្ធអស់មួយចំនួនថ្ងៃជាក់លាក់ ។ សម្រាប់គោ រយៈពេលគឺ ២០ ថ្ងៃ ។ សម្រាប់ចៀមគឺ ១០ ថ្ងៃ ។ សម្រាប់មាន់គឺ ៣ ថ្ងៃ ។

**១២. សំណល់ឈាមក្រោយពីសំឡេះ**

ពេលគេសំឡេះសត្វស្របតាមច្បាប់ស្ហារីអាស៊ុ ហើយឈាមវាបាញ់ចេញមកដោយមានចំនួនគ្រប់គ្រាន់ ឈាមដែលនៅសេសសល់ក្នុងខ្លួនវានោះជាឈាមបរិសុទ្ធ ។

**មេរៀនទី ៨**

# ស្វ៏ឡាត់ យ៉ុមអាត់ (ស្វ៏ឡាត់ ថ្ងៃសុក្រ صلاة الجمعة)

ជាមួយអ៊ីម៉ាំﷺ ឬ ជាមួយអ្នកតំណាងពិសេសរបស់ព្រះអង្គﷺ ស្វ៏ឡាត់ថ្ងៃសុក្រ ជាវ៉ាយ៉ិប អ៊ែនី (កាតព្វកិច្ចលើបុគ្គល) ជួសស្វ៏ឡាត់ស្ហ៊ុស្វរ៍ ។ ក្នុងករណីនេះ គេមិន បំពេញស្វ៏ឡាត់ស្ហ៊ុស្វរ៍ទេ ។

ក្នុងសម័យកាលកុយ់បាស្ងរបស់អ៊ីម៉ាំﷺយើង បើមិនមានអ្នកតំណាងពិសេសទេ ស្វ៏ឡាត់ថ្ងៃសុក្រជា វ៉ាយ៉ិប តាយ៉ិរី ។

អល់ឡោះហ្វ៍ﷻមានព្រះបន្ទូលក្នុងស៊ូរ៉ោះត៍ យ៉ុមអាត់ (៦២:៩) ថា៖

*"អ្នកមានសទ្ធាទាំងឡាយអើយ ពេលគេហៅឲ្យធ្វើនមស្ការនៅថ្ងៃសុក្រ ចូរពួកអ្នក ប្រញាប់ឆ្ពោះទៅរកការរំលឹកដល់អល់ឡោះហ្វ៍ និងចូរទុកចោល[មួយអន្លើសិន]នូវ កិច្ចការជួញដូរ ។ វាជាការប្រសើរបំផុតសម្រាប់ពួកអ្នក បើពួកអ្នកដឹង ។"*

**វ៉ាយ៉ិប តាយ៉ិរី** មានន័យថា គេមានជម្រើសក្នុងពីរជម្រើស តែគេមិនអាចចោលទាំងពីរ វ៉ាយ៉ិបបានទេ ។ ឧទាហរណ៍ ក្នុងរ៉ក់អាត់ទី ៣ និងទី ៤ របស់ស្វ៏ឡាត់ប្រចាំថ្ងៃ គេ ចាំបាច់ត្រូវសូត្រ ស៊ូរ៉ោះត៍ អាល់-ហ្វាំដ៍ ឬ សូត្រ "តាស់ប៊ីហ្វាត់ អារបាអាស់" តែគេ មិនអាចសូត្រទាំងពីរបានទេ ។ ការសូត្រទាំងពីរនេះនៅក្នុងករណី វ៉ាយ៉ិប តាយ៉ិរី ។

មានលក្ខខណ្ឌខ្លះក្នុងស្វ៏ឡាត់ថ្ងៃសុក្រ គឺ៖

១. ស្វ៏ឡាត់ថ្ងៃសុក្រចាំបាច់ប្រព្រឹត្តទៅជាយ៉ាម៉ាអាស់ ។
២. ត្រូវមាន ៥ នាក់ (យកល្អ ៧ នាក់) រាប់ទាំងអ៊ីម៉ាំផង ។
៣. ត្រូវធ្វើស្វ៏ឡាត់ថ្ងៃសុក្រមួយក្នុងរង្វង់ ៥ គីឡូម៉ែត្រ ។ បើមានស្វ៏ឡាត់ពីរនៅក្នុង រង្វង់នេះ ស្វ៏ឡាត់ទីពីរត្រូវមោឃៈ ។

៤. អ៊ីមុាំត្រូវធ្វើឃុត្ហបាស់ពីរមុនស្វំឡាត់ ហើយត្រូវស្តាប់យ៉ាងយកចិត្តទុកដាក់ដោយមនុស្ស ៤ នាក់ (យកល្អ ៦ នាក់)។ ឃុត្ហបាស់ទីមួយត្រូវស្តីអំពីភារកិច្ចធម្មតា ភារកិច្ចរបស់មុស្លីមជាដើម ។ ឃុត្ហបាស់ទីពីរត្រូវស្តីអំពីស្វរ៉ោះត្ត ឬ អាយ៉ាត្តគួរអាន ។

៥. ដូចបានអធិប្បាយនៅខាងលើហើយ មិនមែនវ៉ាយ៊ីបឲ្យបំពេញស្វំឡាត់ថ្ងៃសុក្រដោយដាច់ខាតនោះទេ ។ គេអាចបំពេញស្វំឡាត់ស្ហុស្វរ័ជួសបាន ។ តែបើអ៊ីមុាំអ៊ុឌីល (គឺអ៊ីមុាំត្រឹមត្រូវ) ដឹកនាំស្វំឡាត់ថ្ងៃសុក្រ ជា អិះហ៊្វទីយ៉ាត់ វ៉ាយ៊ីប (إحتياط واجب) ចូលរួមក្នុងស្វំឡាត់នេះ ។

**អិះហ៊្វទីយ៉ាត់ វ៉ាយ៊ីប** មានន័យថា វ៉ាយ៊ីបបង្ការ ។ ដូចវ៉ាយ៊ីបដែរ តែខុសគ្នាត្រង់ដែលថា មុច្ហតាហ៊ីដ្ (مجتهد អ្នកជំនាញខាងច្បាប់សាសនា) មួយចាត់ទុកថាជា "វ៉ាយ៊ីបបង្ការ" តែអនុញ្ញាតឲ្យតាមយោបល់របស់មុច្ហតាហ៊ីដ្ឋម្នាក់ទៀត ពាក់ព័ន្ធនឹងច្បាប់តែមួយ ។ ក្នុងករណីដែលអ្នកជ្រើសរើសយកយោបល់របស់មុច្ហតាហ៊ីដ្ឋម្នាក់ទៀត អ្នកត្រូវចាត់ទុកហ្វាត់វ៉ា(فتوى)របស់មុច្ហតាហ៊ីដ្ឋនេះជាវ៉ាយ៊ីប ហើយប្រតិបត្តិតាមហ្វាត់វ៉ានោះ ។

## របៀបស្វំឡាត់

ស្វំឡាត់ថ្ងៃសុក្រមានពីររ៉ក់អ៊ាត់ ។ ក្នុងរ៉ក់អ៊ាត់ទីមួយ ស្វណាត់ឲ្យសូត្រស្វរ៉ោះត្ត យ៉ុមអ៊ាត់ ក្រោយស្វរ៉ោះត្តអាល់-ហ្វាំដ្ ។ ក្នុងរ៉ក់អ៊ាត់ទីពីរ សូត្រស្វរ៉ោះត្ត មូណាហ្វីគូន ក្រោយស្វរ៉ោះត្ត អាល់-ហ្វាំដ្ ។

## គូនូត

ស្វណាត់ឲ្យសូត្រគូនូតពីរក្នុងស្វំឡាត់នេះ ។ មុនរូគុអ៏ ក្នុងរ៉ក់អ៊ាត់ទីមួយ ក្រោយរូគុអ៏ក្នុងរ៉ក់អ៊ាត់ទីពីរ ។ នេះគឺគូនូតសម្រាប់ស្វំឡាត់ថ្ងៃសុក្រ ។

اَللَّهُمَّ اِنَّ عَبِيْدًا مِّنْ عِبَادِكَ الصَّالِحِيْنَ قَامُوْا بِكِتَابِكَ وَ سُنَّةِ نَبِيِّكَ فَاجْزِهِمْ

عَنَّا خَيْرَ الْجَزَآءِ

អល់ទ្បឹហ្វ៊ុមម៉ា អ៊ីនណា អ៊ុប៊ីដ្វាំ មិន អ៊ីបាឌ្វីកាស្វ៉ ស្វ៍លីហ្ម៊ីន ក៏មូ ប៊ីគ្វីតាប៊ីកា វ៉ា ស៊ុនណាទី ណាប៊ីយីកា ហ្វាច់ស៊ីហ្វ៊ុម អ៊ុន់ណា ខយ់រ៉ល់ យ៉ាសុំអ៊ុំ

អល់ឡោះហ្វ៍អ៊ឺយ បាវបម្រើមួយចំនួនរបស់ព្រះអង្គដែលមានសទ្ធាស៊ប់ចិត្តមាន គោលជំហរមាំមួន ដោយអាស្រ័យលើព្រះគម្ពីរព្រះអង្គនិងទំនៀមរបស់ព្រះសាស្ដា ព្រះអង្គ ។ ព្រះអង្គទ្រង់ព្រះរាជទានរង្វាន់ឲ្យពួកគេ ក្នុងចំណោមអស់ទូលព្រះបង្គំជាខ្ញុំ យ៉ាងប្រសើរបំផុត ។

**មេរៀនទី ៩**

# ស្វ៍ឡាទុល អ៊ីដ៉េន៍ (ស្វ៍ឡាត់ អ៊ីដ្ទទាំងពីរ)

# (صَلَاةُ الْعِيدَيْنِ)

មុស្លីមកាន់បុណ្យធំពីររៀងរាល់ឆ្នាំ ។ បុណ្យទីមួយគឺ អ៊ីដ្ទ អ៊ុល-ហ្វិត្ទរី (عِيدُ الْفِطْرِ - ថ្ងៃទី ១ ខែ ស្ញៅវ៉ាល់) បុណ្យទីពីរគឺ អ៊ីដ្ទ អ៊ុល អាឌ្ហ៍ហ្ា (عيد الأضحى - ថ្ងៃទី ១០ ខែ ស៊ុល ហ៊ីច្ចយ៉ាស់ ذو الحجة) ។ ថ្ងៃទាំងពីរនេះជាបុណ្យធំ ។

អ៊ីដ្ទ អ៊ុល-ហ្វិត្ទរី ប្រព្រឹត្តទៅនៅថ្ងៃដាច់ខែរ៉ម៉ាឌ្ហន ។ ការកាន់សីលត្រណមអាហារធ្វើឲ្យមានអារម្មណ៍សទ្ធាជ្រះថ្លា មានជំនឿ មានអំណត់ មានចិត្តសន្តោស និងមានអារម្មណ៍លះបង់ ។ សម្រាប់មុស្លីម បុណ្យមិនមានន័យថា រាំរែក ឬ ច្រៀងទេ ។ យើងចុះចូលខ្លួនទាំងស្រុងចំពោះអល់ឡោះហ្ទ៍ ដោយថ្វាយស្វ៍ឡាត់អ៊ីដ្ទចំពោះព្រះអង្គដែលយើងបានទទួលនូវអត្ថប្រយោជន៍ផ្លូវសាសនា ផ្លូវអារម្មណ៍សីលធម៌ក្នុងអំឡុងខែរ៉ម៉ាឌ្ហន ។

អ៊ីដ្ទ អ៊ុល អាឌ្ហ៍ហ្ា ប្រព្រឹត្តទៅក្នុងថ្ងៃដែលព្រះសាស្តា អ៊ីបរ៉ហ៊ីមﷺមានបំណងធ្វើពលីកម្ម អ៊ីសម៉ាអ៊ីល រាជបុត្រﷺព្រះអង្គﷺ ដើម្បីគោរពតាមព្រះបញ្ជាអល់ឡោះហ្ទ៍ﷻ ។ គួរអានចែងរឿងរ៉ាវនេះដែលជាគំរូនៃការលះបង់ខ្លួនមួយដ៏មហិមា ។ បុណ្យអាឌ្ហ៍ហ្ាជាការរំលឹកដល់ពលីកម្មនេះ ។ វាដាស់តឿនយើងឲ្យដឹងថាយើងត្រូវតែលះបង់កម្មសិទ្ធិយើងសព្វសារពើដែលយើងមាន រាប់បញ្ចូលជីវិតយើង និងជីវិតរបស់អ្នកជាទីស្រឡាញ់របស់យើងផងដែរ ដើម្បីមាគ៌ាអល់ឡោះហ្ទ៍ﷻ ប្រសិនបើចាំបាច់ត្រូវលះបង់នោះ ។ ក្នុងករណីនេះដែរ យើងថ្វាយអល់ឡោះហ្ទ៍ﷻនូវស្វ៍ឡាត់ពិសេសមួយទៀតគឺ ស្វ៍ឡាត់ អ៊ីដ្ទ ។

ស្វ៍ឡាត់ អ៊ីដ្ទ ជាស៊ូណាត់ក្នុងកុយបាស់របស់អ៊ីមុាំﷺយើង ។

**របៀបស្ហ៊ឡាត់**

នៀតគឺ៖ ខ្ញុំបំពេញស្ហ៊ឡាត់ស៊ូណាត់ អ៊ីដុ្ទ អុល-ហ្វីត្ទរី (ឬ អ៊ីដុ្ទ អុល-អាដ្ហ៉ា) ពីររ៉ក់អាត់ គួរបាតាន់ អ៊ីលឡុលឡោះហ្វ៍ ។

រ៉ក់អាត់ទី ១ ស៊ូណាត់ឲ្យសូត្រស៊ូរ៉ោះត៍ អាល់-អាក់ឡា (៨៧) ក្រោយស៊ូរ៉ោះត៍ អាល់-ហ្វាំដ៍ ។ បន្ទាប់មក សូត្រគួនូត ៥ ដងអមដោយតាក់បៀរ បន្ទាប់មក ធ្វើរូគុអ៍ និង ស៊ូយូ្ជដ្ទ ។

រ៉ក់អាត់ទី ២ ស៊ូណាត់ឲ្យសូត្រស៊ូរ៉ោះត៍ អាស្ហ់-ស្ហាំស៍ (៩១) ក្រោយស៊ូរ៉ោះត៍ អាល់-ហ្វាំដ៍ ។ បន្ទាប់មក សូត្រគួនូត ៤ ដងអមដោយតាក់បៀរ បន្ទាប់មក ធ្វើរូគុអ៍ និង ស៊ូយូ្ជដ្ទ ។

ដូច្នេះ រួមមាន ៩ គួនូត ។

នេះគឺឌូអាអ៍ គួនូត ៖

اَللّٰهُمَّ اَهلَ الْكِبْرِيَاءِ وَالْعَظَمَةِ، وَاَهْلَ الْجُوْدِ وَالْجَبَرُوتِ، وَاَهْلَ الْعَفْوِ وَالرَّحْمَةِ وَاَهْلَ التَّقْوٰى وَالْمَغْفِرَةِ، اَسْاَلُكَ بِحَقِّ هٰذَا الْيَوْمِ الَّذِى جَعَلْتَه لِلْمُسْلِمِيْنَ عِيْدًا وَلِمُحَمَّدٍ صَلَّى اللّٰهُ عَلَيْهِ وَآلِهِ ذُخْراً وَمَزِيْداً اَنْ تُصَلِّيَ عَلٰى مُحَمَّدٍ وَآلِ مُحَمَّدٍ وَاَنْ تُدْخِلَنِى فِى كُلِّ خَيْرٍ اَدْخَلْتَ فِيْهِ مُحَمَّداً وَآلَ مُحَمَّدٍ، وَاَنْ تُخْرِجَنِى مِنْ كُلِّ سُوْءٍ اَخْرَجْتَ مِنْهُ مُحَمَّدًا وَآلَ مُحَمَّدٍ صَلَوَاتُكَ عَلَيْهِ وَعَلَيْهِمْ. اَللّٰهُمَّ اِنِّى اَسْاَ لُكَ خَيْرَمَا سَاَلَكَ عِبادُكَ الصَّالِحُونَ، وَاَعُوْذُ بِكَ مِمَّا اسْتَعاذَ مِنْهُ عِبادُكَ الصَّالِحُونَ

អល់ឡ៉ហ្ហុមម៉ា អាស្ហ់ឡាល់ គីបរ៉អ៊ី វ៉ាល់អាស្ហ៍ម៉ាត់ វ៉ា អាស្ហ់ឡាល់យូ្ជដ្ទ វ៉ាល់-យ៉ា្ជបារូដ វ៉ា អាស្ហ់ឡាល់ អាហ្វរី វ៉ាររ៉ោះហ្មា៍ម៉ាស្ហ់ វ៉ា អាស្ហ់ឡាត់តាក្វ៉ា វ៉ាល់-ម៉ាក់ហ្វីរ៉ោះត៍ អាស់-អាលូកា ប៊ីហ្កាក់គ្វី ហ្ហាស្ហាល់-យ៉ៅមីល-ឡាស្ហ៊ី យ៉ា្ជអាល់តាហ្ហ៊ូ លិលមុស្លីមីណា អ៊ីដ្ទាន់ វ៉ាលីមូហ្វាំម៉ាឌីន ស្ហល់ឡល់ឡ៉ហ្ហ៊ូ អាឡៃហ្ហ៊ី វ៉ា អាលីហ្ហ៊ី ស៊្ហុក់រ៉ន់ វ៉ា ម៉ាស៊្ហីដ្ទាន់ អាន់ ទូស្ហល់លី-យ៉ាក់ឡា មូហ្វាំម៉ាដ្ទ់ វ៉ា អាលី មូហ្វាំម៉ាដ្ទ់ វ៉ា

អាន់-ទុដ្វយីឡានី ហ្វី គុល្លី ខយ់រីន អាដ្វ់ខល់តា ហ្វីហ្លុី មូប្រាំម៉ាដ្វាន់ វ៉ា អាឡា មូប្រាំម៉ាដ្វ់ វ៉ា អាន់-ទុក្ររីយ៉្រានី មិន គុល្លី ស្វអ៊ុីន អាក្រុ់រ៉ុច្រ់តា មិនហ្លូ មូប្រាំម៉ាដ្វាន់ វ៉ា អាឡា មូប្រាំម៉ាដ្វ់ ស្វ៍ឡាវ៉ាទូកា អុាឡៃ្យហ្លុី វ៉ា អុាឡៃ្យហ្លុីម ។

អល់ឡ៍ហ្លុមម៉ា អ៊ីននី អាស់អាលូកា ខយ់រ៉ា ម៉ា-អាស់អាឡាកា អ្រុីបាឌ្វកាស្វ់-ស្វ៍លីហ្ររូន វ៉ា អាអ្វូស្វ្ចប៊ឹកា មីមម៉ាស់តាអុាស្វា មិនហ្លូ អ្រុីបាឌ្វកាស្វ់-ស្វ៍លីហ្ររូន ។

**មេរៀនទី ១០**

# ស៊ីហ្វាត់ ស៊ូប៊ូទីយ៉ាស់ (الصفات الثبوتية)

គុណសម្បត្តិដែលសមសម្រាប់អល់ឡោះហ្វ៍នោះហៅថា "ស៊ីហ្វាត់ ស៊ូប៊ូទីយ៉ាស់" ។ មានច្រើន តែយើងលើកយកមកតែ ៨ ទេ គឺ៖

**១. ក៏ឌីម** (المقدم) មានន័យថា អល់ឡោះហ្វ៍អមតៈ ។ ព្រះអង្គមិនមានដើមកំណើត មិនមានទីបញ្ចប់ ។

**២. ក៏ឌៀរ** (القادر) មានន័យថាអល់ឡោះហ្វ៍មានសព្វានុភាព ។ ព្រះអង្គមានអំណាចលើអ្វីៗសព្វគ្រប់ និងលើសព្វកិច្ចការ ។

**៣. អាលីម** (العليم) មានន័យថាអល់ឡោះហ្វ៍ទ្រង់ញាណសព្វគ្រប់ ។ ព្រះអង្គស្គាល់អ្វីៗសព្វគ្រប់ ។ មិនមានអ្វីមួយឬអ្នកណាមួយអាចលាក់បាំងពីព្រះអង្គបានឡើយ ។ ពុំមានអាថ៌កំបាំងសម្រាប់ព្រះអង្គឡើយ ។

**៤. ហៃ** (الحي) មានន័យថាអល់ឡោះហ្វ៍ទ្រង់គង់នៅជានិច្ច ។

**៥. មូរីដ្** (المريد) មានន័យថាអល់ឡោះហ្វ៍ទ្រង់មានមូលហេតុរបស់ព្រះអង្គផ្ទាល់ក្នុងកិច្ចការនីមួយៗ ។ ព្រះអង្គមិនធ្វើអ្វីមួយតាមតែក្បាលចិត្ត ឬដោយឥតគិតគូរនោះទេ ។

**៦. មុដ្ររិក** (المودريك) មានន័យថាអល់ឡោះហ្វ៍ទ្រង់ទស្សនាការ ព្រះអង្គទ្រង់សវនាការដោយមិនចាំបាច់មានភ្នែកឬត្រចៀកទេ ។

**៧. មូតាកាល់លិម** (المتكلم) មានន័យថាអល់ឡោះហ្វ៍ជាព្រះម្ចាស់ពិភពលោក ។ ព្រះអង្គ

ធ្វើឲ្យអ្វីមួយនិយាយបានស្រេចតែលើព្រះអង្គ ដូចដែលព្រះអង្គបានធ្វើឲ្យដើមឈើនិយាយបានជាមួយមូសា ﷺ ហើយឲ្យ "វាំងននពន្លឺ" និយាយជាមួយព្រះសាស្តា ﷺ បាន ។

**៨. ស្វ៉ាឌិក្ហ** (الصادق) មានន័យថាអល់ឡោះហ្ទ៍មានសច្ចធម៌ក្នុងព្រះបន្ទូលនិងក្នុងពាក្យសន្យាព្រះអង្គ ។

# ស្វីហ្វាត់ សាល់ប៊ីយ៉ាស់ (الصفات السلبية)

គុណវិបត្តិដែលគេមិនឃើញមានលើអល់ឡោះហ្ទ៍ ។ មានច្រើនផងដែរ តែយើងលើកយកមកតែ ៨ ទេ គឺ៖

**១. ស្ហារីក** (شرك) ពាក្យថា "ស្ហារីក" មានន័យថា ដៃគូ អ្នកមានវិជ្ជាជីវៈដូច ឬសហការី ។ អល់ឡោះហ្ទ៍មិនមានសហការីឬដៃគូទេ ។

**២. មូរ៉ក់កាប់** (مركب) មានន័យថា ល្បាយចម្រុះ ឬ លាយ ។ អល់ឡោះហ្ទ៍មិនកើតមកពីអ្វីទេ ។ មិនអាចបែងចែកព្រះអង្គបានឡើយ ទោះបីក្នុងសេចក្តីស្រមៃក៏ដោយ ។

**៣. ម៉ាកាអាន់** (مكان) មានន័យថា កន្លែង ។ អល់ឡោះហ្ទ៍មិនមានទីកន្លែងជាស្ថាពរទេ មិនមានខ្លួនប្រាណទេ ។ ព្រះអង្គទ្រង់គង់នៅសព្វទីកន្លែង ។

**៤. ហ៊ូលុល** (حلول) មានន័យថា ចូល ។ មិនមានអ្វីមួយអាចចូលក្នុងអល់ឡោះហ្ទ៍បានឡើយ ។ ព្រះអង្គមិនចូលក្នុងរូបកាយនិងវត្ថុទេ ។ ឧទាហរណ៍ ពួកគ្រិស្តគិតថាយេស៊ូរស់ឡើងវិញ ទៅជាវិញ្ញាណរបស់ព្រះ ។

**៥. ម៉ាហ៊ុាលី ហ៊ុាវ៉ាឌីស្ហ** មានន័យថា រមែងតែផ្លាស់ប្តូរ ។ អល់ឡោះហ្ទ៍មិនផ្លាស់ប្តូរតាម

ពេលវេលាទេ ។

**៦. ម៉ារអ៊ី** (مرئي) មានន័យថា អាចមើលឃើញ ។ គេមិនដែលមើលឃើញព្រះអង្គឡើយ ហើយនឹងមិនឃើញព្រះអង្គឡើយ ព្រោះព្រះអង្គមិនមានខ្លួនទេ ។

**៧. អិុះហ្ទ៍ទីយ៉ាច់** មានន័យថា នៅក្នុងចំណុះគេ ឬ ត្រូវការ ។ អល់ឡោះហ្ទ៍មិននៅក្នុងចំណុះអ្នកណាឡើយ ហើយក៏មិនត្រូវការអ្នកណាឡើយ ។

**៨. ស្ទីហ្វាត់ ស្ារអ៊ីដ្** (صفت زائد) មានន័យថា គុណសម្បត្តិដែលរកបាន ។ គុណសម្បត្តិអល់ឡោះហ្ទ៍មិនអាចញែកចេញបានពីព្រះអង្គឡើយ ។ ឧទាហរណ៍ យើងថា អល់ឡោះហ្ទ៍ជាអាុលីម មិនមានន័យថាការចេះដឹងរបស់ព្រះអង្គបែកផ្សេងពីព្រះអង្គនោះទេ ។ មិនដែលមានពេលណាមួយដែលព្រះអង្គមានការចេះដឹងតិចជាងពេលណាមួយទៀតឡើយ ។

**មេរៀនទី ១១**

# ម៉ាសាអ៊ីល យ៉ាប៊ីរ៉ោះត៍ (جَبِيرَة)

**អ្វី យ៉ាប៊ីរ៉ោះត៍?**

ការរុំ (ចងបន្ទះឈើ ឬ បូកម្នាងសិលា) លើរបួសឬឆ្អឹងបាក់ ឬការចតថ្នាំលើរបួសក៏ហៅថា យ៉ាប៊ីរ៉ោះត៍ដែរ ។

ក្នុងនីតិសាស្ត្រអ៊ីស្លាម (គឺហ្វីកោះហ្វអ៊ីស្លាម) យ៉ាប៊ីរ៉ោះត៍គឺវត្ថុឬថ្នាំប្រើសម្រាប់រុំ (ប៉ង់សឺម៉ង់) ឬ ចង ។

វូឌូអ៍ អាល់-យ៉ាប៊ីរ៉ោះត៍ មានន័យថា វូឌូអ៍លើក្រណាត់សំពត់រុំរបួស ឬលើព្រួលស្វប ដែលចងជាប់ប៉ែកមួយរបស់រូបកាយដែលត្រូវយកទឹកវូឌូអ៍ ។

**យកទឹក វូឌូអ៍ អាល់-យ៉ាប៊ីរ៉ោះត៍ នៅពេលណា?**

វូឌូអ៍ អាល់-យ៉ាប៊ីរ៉ោះត៍ ប្រើបានតែក្នុងករណីដូចតទៅគឺៈ

១. បើក្រណាត់រុំរបួសដែលមានស្បែកមុតឬរលាត់ កុំឲ្យតែក្រណាត់នោះរុំជិតទាំងស្រុងប៉ែកដែលត្រូវយកទឹកវូឌូអ៍ ។

២. ពេលមានព្រួលស្វបអមអវយវៈណាមួយ កុំឲ្យតែក្រណាត់នោះរុំជិតទាំងស្រុងប៉ែកដែលត្រូវយកទឹកវូឌូអ៍ ។

**វូឌូអ៍ អាល់-យ៉ាប៊ីរ៉ោះត៍**

| | |
|---|---|
| រុំលើស្បែកមុតឬរលាត់<br>+<br>មិនត្រូវរុំជិតទាំងស្រុងប៉ែកដែលត្រូវយកទឹកវូឌុអ៊ុំនោះទេ ។ | ព្រួលស្ទបអមឆ្អឹងបាក់<br>+<br>មិនត្រូវរុំជិតទាំងស្រុងប៉ែកដែលត្រូវយកទឹកវូឌុអ៊ុំនោះទេ ។ |

**សំណួរ**

តើត្រូវយកទឹកវូឌុអ៊ុំរបៀបណា បើក្រណាត់រុំឬព្រួលស្ទបគ្របជិតប៉ែកដែលត្រូវយកទឹកវូឌុអូលើ ?

ក្នុងករណីនេះ

| | |
|---|---|
| បើប៉ែកដែលត្រូវរុំជិតនោះជាជើងមួយ ឬជើងទាំងពីរ ឲ្យធ្វើតាយ៉ាំមុម | បើប៉ែកដែលត្រូវរុំជិតនោះជាខ្នងដៃ ឬមុខ ឲ្យយកទឹកវូឌុអ៊ុំ អាល់-យ៉ាប៊ីរ៉េាះត្វ៍ |

បើអាចលាងរបួសដោយយកក្រណាត់រុំចេញបាន ចាំបាច់ត្រូវយកទឹកវូឌុអ៊ុំធម្មតា ។ បើមិនអាចយកក្រណាត់រុំចេញបានទេ ឲ្យយកដៃជូតលើក្រណាត់រុំទាំងស្រុង ។

ប្រសិនបើក្រណាត់នោះរុំលើរបួសស្រាល ឬគ្រាន់តែជាការតែងលំអទេ ចាំបាច់ត្រូវយកទឹកវូឌុអ៊ុំធម្មតា បើធ្វើទៅបាន ។ ពុំនោះទេ ឲ្យធ្វើតាយ៉ាំមុម ។

**យ៉ាប៊ីរ៉េាះត្វ៍ - ពេលណាធ្វើតាយ៉ាំមុម ពេលណាយកទឹកវូឌុអ៊ុំ**

១. បើមានរបួសបើកមុខ ឬបាក់ឆ្អឹង ត្រង់ប៉ែកដែលត្រូវយកទឹកវូឌុអ៊ុំនោះ (ប៉ែករូបកាយដែលគេយកទឹកវូឌុអ៊ុំ រាប់បញ្ចូលការជូតម៉ាសាស្ហ៊ដែរ ក្បាលនិងជើង) បើទឹកមិនធ្វើឲ្យមានគ្រោះថ្នាក់ទេ ចាំបាច់ត្រូវយកទឹកវូឌុអ៊ុំធម្មតា ។

២. បើមានរបួសបើកមុខ ឬបាក់ឆ្អឹង លើដៃ ហើយបើទឹកធ្វើឲ្យមានគ្រោះថ្នាក់ ត្រូវលាងប៉ែកជុំវិញរបួសពីលើមកក្រោម យកល្អឲ្យយកដៃទទឹកជូតលើកន្លែងរបួស

(ដូចគេម៉ាសាស្ហ៍ដែរ) បើមិនធ្វើឲ្យមានគ្រោះថ្នាក់ទេ ។ បន្ទាប់មក យកក្រណាត់បរិសុទ្ធរុំលើមុខរបួសហើយយកដៃទទឹកជូតលើក្រណាត់ម្ដងទៀត ។

៣. បើមានរបួសបើកមុខ ឬបាក់ឆ្អឹង លើក្បាលប៉ែកខាងមុខ ឬ លើជើង ដែលមិនអាចម៉ាសាស្ហ៍ (គឺជូត) បានទេ ចាំបាច់ត្រូវធ្វើតាយ៉ាំមុមមុន បន្ទាប់មកយកទឹកវូឌ្មុអ៍អាល់-យ៉ាប៊ីរ៉ោះត៍ ។ ត្រូវរុំមុខរបួសដោយក្រណាត់បរិសុទ្ធ ហើយម៉ាសាស្ហ៍ (គឺជូត) ពីលើ ។

៤. បើមុខរបួសត្រូវរុំពីលើ ហើយអាចត្រូវទឹកបានដោយមិនធ្វើឲ្យមានគ្រោះថ្នាក់ទេ ត្រូវយកវត្ថុរុំចេញ ហើយយកទឹកវូឌ្មុអ៍ធម្មតា ។

៥. បើមិនអាចយកក្រណាត់រុំចេញពីមុខរបួសបានទេ ហើយក្រណាត់រុំនិងមុខរបួសនោះស្អាត ហើយបើទឹកអាចទៅដល់មុខរបួសបាន (ដោយជ្រាបតាមក្រណាត់រុំ) ដោយមិនធ្វើឲ្យមានគ្រោះថ្នាក់ ចូរឲ្យយកទឹកវូឌ្មុអ៍តាមរបៀបដែលទឹកអាចជ្រាបដល់ទៅមុខរបួសបាន ។

៦. ពេលណាមិនងាយយកក្រណាត់រុំចេញបានទេ ហើយមុខរបួសក្នុងក្រណាត់រុំនោះណាយ៉្លីស មុនយកទឹកវូឌ្មុអ៍ ត្រូវធ្វើឲ្យវាទាំងពីរនេះបរិសុទ្ធស្អាតសិន ។ តែក្នុងករណីដែលមិនអាចធ្វើទៅបានទេ ឬមានគ្រោះថ្នាក់ពេលសម្អាតឲ្យបរិសុទ្ធនោះ ត្រូវធ្វើតាយ៉ាំមុម ។

៧. បើមុខនិងដៃមួយឬដៃទាំងពីរត្រូវរុំជិតអស់តែម្ដង ត្រូវធ្វើតាយ៉ាំមុមបន្ទាប់មកត្រូវយកទឹកវូឌ្មុអ៍លើក្រណាត់រុំ ។

៨. សំលៀកបំពាក់ស្ហ៍ឡាត៍មិនត្រូវធ្វើអំពីស្បែកសត្វហារ៉ាំទេ ឬធ្វើអំពីសូត្រទេ (សម្រាប់បុរស) ។ តែមិនខុសទេបើក្រណាត់រុំនោះធ្វើអំពីវត្ថុទាំងនេះ ។

៩. បើមានក្រណាត់រុំលើបាតដៃនិងលើម្រាមដៃ ហើយបើដៃទទឹកជូតលើក្រណាត់រុំនោះក្នុងពេលយកទឹកវូឌ្មុអ៍ ពេលជូត (ម៉ាសាស្ហ៍) ក្បាលឬជូតជើង ត្រូវប្រព្រឹត្តទៅ

ជាមួយទឹកតែមួយនេះដែលទទឹកក្រណាត់រុំដៃនេះ ។ នៅលើប៉ែកដែលត្រូវយកទឹកវូឌុអ៊ុំនោះ បើមានអ្វីផ្សេងពីថ្នាំ ដែលពិបាកយកចេញ ឧទាហរណ៍ថ្នាំលាបជាដើម ត្រូវធ្វើតាយ៉ាំមុម ។

១០. ស្រដៀងវូឌុអ៊ុំដែរ ច្បាប់ពាក់ព័ន្ធនឹងក្រណាត់រុំប្រើសម្រាប់គុសល៍ដែរ ។ ក្នុងករណីនេះ អនុញ្ញាតចំពោះតែ គុសល៍ តារទីប៊ី ទេ (មិនអាចប្រើ គុសល៍ អៀរទីម៉ាសី (الارتماسى) បានទេ ។

១១. ក្នុងករណីដែលមានរបួសលើប៉ែកណាមួយនៃរូបកាយ ហើយចាំបាច់ត្រូវវង្វតទឹកគុសល៍ ឲ្យជ្រើសរើសយកតាយ៉ាំមុម ឬ យកគុសល៍ ដោយអនុវត្តិតាមច្បាប់ យ៉ាប៊ីរ៉ោះត៍ ។

១២. ប្រសិនបើអ្នកណាមិនប្រាកដថាត្រូវយកទឹកវូឌុអ៊ុំឬត្រូវធ្វើតាយ៉ាំមុម ឲ្យអ្នកនោះធ្វើទាំងពីរ ។

**មេរៀនទី ១២**

# ពាក្យបច្ចេកទេសអ៊ីស្លាម

**១. យ៉ាស្ហ់រីយ៉ាស្ហ់ និង អ៊ិះខ៍ហ្វាទីយ៉ាស្ហ់** (صلاة جهرية صلاة اخفاتية)

ច្បាប់យ៉ាស្ហ់រីយ៉ាស្ហ់និងអ៊ិះខ៍ហ្វាទីយ៉ាស្ហ់ប្រតិបត្តិលើស្វ៍ឡាត្ហ់ប្រចាំថ្ងៃទាំង ១៧ រ៉ក់អាត់្ហ ។

សម្រាប់បុរស ៖

ស្វ៍ឡាត្ហ់ ហ្វាច្ញរ៍ ម៉ាក់្ហរីប និង អ៊ីស្ហាអ៍ ជាប្រភេទស្វ៍ឡាត្ហ់ យ៉ាស្ហ់រីយ៉ាស្ហ់ ពោលគឺ ត្រូវសូត្រស្វ៍ឡាត្ហ់ទាំងនេះដោយប្រើសម្លេងខ្លាំង ដូចយ៉ាងបើមានអ្នកណានៅក្នុង បន្ទប់ស្វ៍ឡាត្ហ់ អ្នកអាចឮគេសូត្រ ។ ក៏ប៉ុន្តែត្រូវសូត្រ តាស់ប៊ីហ៊្ហាត្ហ់ អារបាអ៊ុស្ហ់ ដោយប្រើសម្លេងខ្សោយ ។

ស្វ៍ឡាត្ហ់ ស្ហ៊ុស្ហរ៍ និង អ៊ាស្វ៍រ៍ អនុវត្តិតាមច្បាប់អ៊ិះខ៍ហ្វាទីយ៉ាស្ហ់ ពោលគឺ ត្រូវសូត្រ គ្រប់រ៉អាត់ និង តាស់ប៊ីហ៊្ហាត្ហ់ អារបាអ៊ុស្ហ់ ដោយប្រើសម្លេងខ្សោយ ។ ក៏ប៉ុន្តែអាច សូត្រស៊ីករ៉ងទៀតដោយប្រើសម្លេងខ្លាំងបាន ។

សម្រាប់ស្ត្រី ៖

ស្វ៍ឡាត្ហ់ ហ្វាច្ញរ៍ ម៉ាក់្ហរីប និង អ៊ីស្ហាអ៍ ជាប្រភេទស្វ៍ឡាត្ហ់ យ៉ាស្ហ់រីយ៉ាស្ហ់ ពោលគឺ ត្រូវសូត្រ ស្វ៍ឡាត្ហ់ទាំងនេះដោយប្រើសម្លេងខ្លាំង លើកលែងតែ តាស់ប៊ីហ៊្ហាត្ហ់ អារបាអ៊ុស្ហ់ ។

ស្វ៍ឡាត្ហ់ ស្ហ៊ុស្ហរ៍ និង អ៊ាស្វ៍រ៍ ជាប្រភេទស្វ៍ឡាត្ហ់ អ៊ិះខ៍ហ្វាទីយ៉ាស្ហ់ ពោលគឺ មិនត្រូវសូត្រដោយប្រើសម្លេងខ្លាំងទេ ។

**២. វ៉ាយ៉ិប អាល់-អ៊ែនី**

គឺវ៉ាយ៉ិបដែលចាំបាច់លើបុគ្គលគ្រប់រូប ។ ឧទាហរណ៍ ស្វ៉ឡាត់ ។

**៣. វ៉ាយ៉ិប អាល់-ហ្វៅរី**

គឺវ៉ាយ៉ិបដែលទៅជាចាំបាច់ដោយសារតែវ៉ាយ៉ិបមួយទៀត ។ ឧទាហរណ៍ អ្នកសម្រេចចិតទៅបំពេញពិធីហ្ចាជ្ជមុនបានទៅជា "មុសតាត់អ៊ី" អ្នកចាំបាច់ត្រូវបង់ប្រាក់ឃុមស៍ឲ្យរួចសព្វគ្រប់សិនដែលជាវ៉ាយ៉ិបមួយផងដែរ ។

**៤. វ៉ាយ៉ិប តាយ៉ីរី**

គឺវ៉ាយ៉ិបតាមជម្រើស ។ ឧទាហរណ៍ ក្នុងរ៉ក់អាត់ទី ៣ និង ទី ៤ របស់ស្វ៉ឡាត់ប្រចាំថ្ងៃ វ៉ាយ៉ិបឲ្យសូត្រស៊ូរ៉ោះត៍ "អាល់-ហ្វាំដ៍" ឬ "តាស់ប៊ីហ្វាត់ អារបាអាស់" ។ អ្នកអាចជ្រើសរើសយកមួយណាក៏បាន តែមិនអាចចោលទាំងពីរបានទេ ។

**៥. វ៉ាយ៉ិប គីហ្វាអ៊ី**

គឺវ៉ាយ៉ិបចាំបាច់លើទាំងអស់គ្នា តែបើមានអ្នកណាម្នាក់បានបំពេញវ៉ាយ៉ិបនេះត្រឹមត្រូវហើយ អ្នកឯទៀតមិនបាច់ធ្វើទេ ។ ឧទាហរណ៍ មានមនុស្សមួយក្រុមនៅក្នុងសាល បុគ្គលណាម្នាក់បានចូលមកដោយថា "អាស់សាឡាមូ អាឡៃគុម" ។ ទាំងអស់គ្នាចាំបាច់ត្រូវឆ្លើយតបវិញ ទាល់តែមានអ្នកណាម្នាក់ឆ្លើយតបវិញថា "អាឡៃគុម សាឡាម" ។ ឧទាហរណ៍មួយទៀតគឺ គុសល៍ កាហ្វាន់ និង ស្វ៉ឡាត់ម៉ាយិត ។ ជាវ៉ាយ៉ិបលើទាំងអស់គ្នា បើមានអ្នកណាម្នាក់ស្ម័គ្រចិត្តធ្វើកាតព្វកិច្ចនេះ អ្នកឯទៀតមិនបាច់ធ្វើទេ ។ ក្នុងករណីនេះ យកល្អឲ្យអ្នកស្ម័គ្រចិត្តបញ្ជាក់ក្នុងនៀតថា "វ៉ាយ៉ិប គីហ្វាអ៊ី" ។

**មេរៀនទី ១៣**

# អាស៊ុកាមុល អ៊ីសទីបរ៉អ៍

**អ្វី អ៊ីសទីបរ៉អ៍?**

អ៊ីសទីបរ៉អ៍គឺទង្វើសូណាត់សម្រាប់បុរសក្រោយពីបត់ជើងតូច។ ដើម្បីធានាថាទឹកនោមមិនមានសល់នៅក្នុងអង្គជាតទេ។ ចូររំលឹកថាទឹកនោមជាណាយ៉ិស បើមិនជម្រះឲ្យត្រឹមត្រូវទេ ខ្លួននិងសំលៀកបំពាក់អាចទៅជាណាយ៉ិសដែរ ទង្វើ(អាុម៉ាល់)ទាំងឡាយ ដូចជាស្វ៍ឡាត់ ជាដើម នឹងមោឃៈក្នុងពេលមានណាយ៉ិសនេះ។ សូមរំលឹកឡើងវិញថាអ៊ីស្លាមដាក់មកជាវ៉ាយ៉ិបនូវបីពេលស្វ៍ឡាត់ (គឺ ៥ ស្វ៍ឡាត់) ក្នុងមួយថ្ងៃ។ ដូច្នេះអ្នកចាំបាច់ត្រូវរក្សាខ្លួនឲ្យស្អាត ឲ្យបានញឹកញយ តាមដែលអាចធ្វើទៅបានក្នុងមួយថ្ងៃ។

**របៀបអ៊ីសទីបរ៉អ៍**

ទង្វើខាងក្រោមនេះជាវិធីយកទឹកនោមដែលនៅសល់ចេញ។

១. ប្រសិនបើក្រោយពីបត់ជើងតូចរួច គូថ (ទ្វារឧច្ចារៈ) ទៅជាណាយ៉ិសដែរ ដំបូងត្រូវធ្វើឲ្យបរិសុទ្ធសិន ៣ ដង។ ឬទាប់មក ត្រូវសង្កត់ ៣ ដង លើប៉ែកដែលនៅត្រង់ចន្លោះគូថនិងគល់អវយវៈនោម ដោយម្រាមដៃកណ្ដាលរបស់ដៃឆ្វេង។

២. បន្ទាប់មក ធ្វើចលនាមករកខាងចុងអវយវៈនោម ដោយសង្កត់អវយវៈនោមដោយចង្អុលដៃនិងមេដៃរបស់ដៃឆ្វេង។

៣. ចុងក្រោយ រលាស់ចុងអវយវៈនោម ៣ ដង មុននឹងលាងវាដោយទឹក យ៉ាងហោចណាស់ ២ ទៅ ៣ ដង។

**ផលប្រយោជន៍របស់អ៊ីសទីប៉រ៉ុំ**

ប្រសិនបើក្រោយពីបានធ្វើអ៊ីសទីប៉រ៉ុំហើយ មានទឹកអ្វីមួយចេញមកទៀត ហើយគេមិនដឹងថាទឹកនោះជាទឹកនោមឬមិនមែនទឹកនោមទេ អ្នកនៅតែបរិសុទ្ធដដែល ។ អ្នកមិនដាច់ត័ហ្វារ៉ត់ទេដោយសារអ៊ីសទីប៉រ៉ុំរបស់អ្នក ។

ប្រសិនបើអ្នកមិនបានធ្វើអ៊ីសទីប៉រ៉ុំទេ អ្នកត្រូវតែសន្មតថាទឹកនោះជាទឹកនោម អ្នកត្រូវធ្វើឲ្យខ្លួនអ្នកបរិសុទ្ធ ។

## លំហាត់ ១

ក. ចូរគូសភ្ជាប់ជាមួយចម្លើយត្រឹមត្រូវ ។

| | |
|---|---|
| -ភាពស្មើគ្នាក្នុងសាសនាអ៊ីស្លាម | -ឧទាហរណ៍ លើសពី ១០ នាក់ក្នុងស្ម័្រឡាត់យ៉ាម៉ាអាុស់ ។ |
| -ឯកភាព | -តម្រៀបជួរ រូគុអ៊ុ ចុះសាច់ដ្ឋាស់ ។ល ។ ក្រោយអ៊ីម៉ាំ ។ |
| -សេចក្តីស្រឡាញ់និងសហប្រតិបត្តិការ | -ម៉ាស់យ៉ីដ្ឋយើងមានមនុស្សអ៊ូអរ ។ |
| -វិន័យ | -នៀតតែមួយ ភាសាតែមួយ ទង្វើដូចគ្នា ។ |
| -កិត្យានុភាពរបស់អ៊ីស្លាម | -អ្នកមាន អ្នកក្រ តូច ធំ ទាំងអស់គ្នាឈរទន្ទឹមស្មាគ្នា |
| -រង្វាន់ឥតព្រំដែន | -មនុស្សជួបជុំគ្នា បណ្ដាលឲ្យកើតមាននូវមិត្តភាពនិងការរាប់អានគ្នាទៅវិញទៅមក ។ |

ខ. លំហាត់ដូចគ្នា

| | |
|---|---|
| -ម៉ាក់មុម | -អ្នកគ្រប់អាយុ ដឹងខុសត្រូវ ។ |
| -យ៉ាម៉ាអាុស់ | -អ្នកស្ម័្រឡាត់ពីក្រោយអ៊ីម៉ាំ ។ |
| -អ៊ីម៉ាំ | -អ្នកនាំមុខស្ម័្រឡាត់ ។ |
| -បាលីកុ | -ប្រជុំ ។ |

## លំហាត់ ២

ក. ចូរសរសេរ "ខ" (ខ្លាំង) "ត" (តិចៗ) នៅលើតារាងសូត្ររបស់អ៊ីម៉ាំយ៉ាម៉ាអាុស់ ។

| សូត្រ | ស្ទុំស្វរ | ម៉ាក់រីប |
|---|---|---|
| | | |
| ស្វរ៉ោះត្ អាល់-ហ្វាំដ្វ | | |
| បិសមិលឡាហ្វៀរ រ៉ោះហ្វម៉ាន-នៀររ៉ហ្វីម | | |
| គុនូត | | |
| តាស់បីហ្វាត់ អារបាអាត្ស | | |
| ស៊ុីករ៍ រូគុអ៍ | | |
| ស៊ុីករ៍ សាច់ដ្វាស់ | | |
| តាស្ហាស្វហ្វដ្វ និង សាឡាម | | |
| ស្វរ៉ោះត្ទី ២ ក្រោយ អាល់-ហ្វាំដ្វ | | |

ខ. តើអ្នកធ្វើដូចម្ដេចក្នុងករណីនេះ គឺៈ

១. អ្នកទៅម៉ាស់យ៉ីដ្វដើម្បីចូលរួមស្វ៍ឡាត្ស្ទុំស្វរ៍ តែអ្នកមិនដឹងថាស្វ៍ឡាត្ដល់រ៉ក់អាត្ណាហើយទេ ដែលកំពុងតែគ្នីយ៉ាមនោះ ?

២. អ្នកចូលរួមក្នុងស្វ៍ឡាត្យ៉ាម៉ាអាត្ស ក្នុងរ៉ក់អាត្ទី ៣ ។ អ៊ីមុាំរូគុអ៍ ហើយងើបឡើងវិញ តែអ្នកសូត្រមិនទាន់ចប់ស្វរ៉ោះត្ អាល់-ហ្វាំដ្វទេ ?

៣. អ្នកចង់រូគុអ៍តាមអ៊ីមុាំ តែខ្លាចអ៊ីមុាំងើបឡើងវិញមុនអ្នកតាមទាន់ ?

## លំហាត់ ៣

ក. អ្នកចូលរួមក្នុងស្វ៍ឡាត្ម៉ាក់រីប ពេលដែលគេកំពុងតែឈរគ្នីយ៉ាមរ៉ក់អាត្ទី ២ (នេះជា រ៉ក់អាត្ទី ១ សម្រាប់អ្នក) ។ ប៉ែកខាងឆ្វេងតារាងខាងក្រោមនេះជាទង្វើនិងការសូត្ររបស់អ៊ីមុាំ ។ ចូរសរសេរលើប៉ែកខាងស្ដាំតារាងនូវទង្វើនិងការសូត្រដែលអ្នកនឹងធ្វើ ។

| រ៉ក់អាត់ទី ២ របស់អ៊ីម៉ាំ | រ៉ក់អាត់ទី ១ របស់អ្នក |
|---|---|
| | |
| ស្វ៉េះត៍ អាល់-ហ្វាំង៍ | |
| គ្នូនូត | |
| រុគុអ៊ូ | |
| សាច់ដ្ហាស៍ | |
| តាស្ហាស៍ហ្វីដ | |
| ងើបឡើងធ្វើរ៉ក់អាត់ទី ៣ | |
| | |
| **រ៉ក់អាត់ទី ៣ របស់អ៊ីម៉ាំ** | **រ៉ក់អាត់ទី ២ របស់អ្នក** |
| | |
| តាស់ប៊ីហ្វាត់ អារបាអាស៍ | |
| រុគុអ៊ូ | |
| សាច់ដ្ហាស៍ | |
| តាស្ហាស៍ហ្វីដ | |
| សាឡាម | |

ខ. បើស៊្វឡាត់យ៉ាម៉ាអាស៍ដំណើរការដល់ឥរិយាបថខាងក្រោមនេះ តើអ្នកអាចចូលរួមបានទេ ? ចូរឆ្លើយថា "បាន" ឬ "ទេ" ។

| | |
|---|---|
| គ្នូនូត | |
| គ្នីយ៉ាមក្រោយរុគុអ៊ូ | |
| ក្នុងចន្លោះសាច់ដ្ហាស៍ទាំងពីរ | |
| គ្នីយ៉ាមរ៉ក់អាត់ទី ១ | |
| សាឡាម | |
| សាច់ដ្ហាស៍ចុងក្រោយបង្អស់ក្នុងរ៉ក់អាត់ចុងក្រោយបង្អស់ | |
| តាស្ហាស៍ហ្វីដ | |

គ. ស្វឡាត់ណាខ្លះដែលអាចធ្វើជុំគ្នាបានជាយ៉ាម៉ាអុស្ វ ? ចូរគូសជុំវិញចម្លើយត្រឹមត្រូវ ។

១) វ៉ាស្វស្វាត់(الوحشة) ២) ស្វុបហ្វ ៣) អ៊ីដ្វខ្មែន ៤) យ៉ុមអុាត់(ថ្ងៃសុក្រ)
៥) ស៊្វុស្វរ ៦) ម៉ាកុរិប ៧) ស្វឡាត់ ម៉ាឃិត ៨) អុាស្វរ
៩) អ៊ីសទិសក៏អ៊ុ(الإستسقاء)

ឃ. អ្នកចង់ដឹកនាំស្វឡាត់យ៉ាម៉ាអុស្វស៊្វុស្វរ

១) អ្នកត្រូវ________________ ________________ ________________ ________________ គ្រប់វ័យអាចសូត្របានយ៉ាងត្រឹមត្រូវ ។

២) តើអ្នកអាចស្វឡាត់ពីក្រោយអ៊ីម៉ាំមុស្លីមស៊ុន្នីបានទេ ? ចូរអធិប្បាយចម្លើយរបស់អ្នក ។

## លំហាត់ ៤

ចូរឆ្លើយសំណួរដោយជ្រើសរើសយកចម្លើយត្រឹមត្រូវ និងដោយសរសេរតួអក្សរតំណាងចម្លើយ ។

១. ហ្វាដ្វាស្វ(ធំ)ទាមទារទង្វើខាងក្រោមនេះដើម្បីធ្វើឲ្យបរិសុទ្ធវិញ គឺៈ

ក) នៀត + វ៉ុឌុអ៊ុ
ខ) នៀត + គុសល៍
គ) វ៉ុឌុអ៊ុ + គុសល៍

២. ទឹកនោមនិងលាមករបស់សត្វមានជីវិតខាងក្រោមនេះជាណាយ៉ីស គឺសត្វៈ

ក) ដែលឈាមបាញ់ ហើយសាច់របស់វាហ្វាឡាល់បរិភោគ ។

ខ) ដែលឈាមបាញ់ ។

គ) ដែលឈាមបាញ់ ហើយសាច់របស់វាហ្វារ៉ាំបរិភោគ ។

៣. វត្ថុទាំង ៣ ខាងក្រោមនេះ មួយណាទាមទារឲ្យមាននៀតដើម្បីធ្វើឲ្យបរិសុទ្ធ គឺ៖

ក) ស្រា ។

ខ) សាកសព ។

គ) ឈាម ។

៤. សាច់ជ្រូកជាណាយ៉ីសព្រមទាំងហ្វារ៉ាំផង ។ ក៏ប៉ុន្តែរោមវា ក្រចកវា ឆ្អឹងវា ធ្មេញវា បរិសុទ្ធទាំងអស់ ។ ការអះអាងនេះ...

ក) ខុស ខ) ត្រូវ គ) មិនត្រូវ មិនខុស

៥. វត្ថុណាយ៉ីសធ្វើឲ្យវត្ថុមួយទៀតទៅជាណាយ៉ីសដោយការប៉ះពាល់ ប្រសិនបើ...

ក) វត្ថុណាមួយក្នុងចំណោមវត្ថុទាំងពីរនេះទទឹកឬសើម ។

ខ) វត្ថុណាមួយ ឬ វត្ថុទាំងពីរស្ងួត ។

គ) មិនមានវាក្យសម្ព័ន្ធណាមួយខាងលើនេះត្រឹមត្រូវទេ ។

៦. មួយណាមិនត្រូវនៅក្នុងចំណោមបីនេះគឺ៖

ក) ឆ្កែ

ខ) ជ្រូក

គ) គោ

៧. ឈាមសត្វមួយរបស់សត្វខាងក្រោមនេះមិនមែនណាយ៉ីស គឺ៖

ក) ពស់ ។

ខ) មនុស្ស ។

គ) ចៀម ។

៨. អ្វីដែលច្បាប់ស្វារីអ៊ុស្វ៉ហៅថាមិនបរិសុទ្ធគឺះ

ក) ត៍្ហហៀរ ។

ខ) ណាយ៉ឺស ។

គ) បរិសុទ្ធ ។

៩. ណាយ៉ាសាស្វ៉មានពីរប្រភេទ ពឹងផ្អែកលើករណីខាងក្រោមនេះ គឺះ

ក) ដើមកំណើតរបស់ណាយ៉ាសាស្វ៉គឺមនុស្ស ឬ សត្វ ។

ខ) វិធីសម្រាប់ជម្រះឲ្យបរិសុទ្ធ ។

គ) ដើមកំណើតរបស់ណាយ៉ាសាស្វ៉ជាវត្ថុមានជីវិត ឬគ្មានជីវិត ។

១០. សាកសពជាណាយ៉ឺស (ច្រើនម៉ោងក្រោយពីបានស្លាប់) មុនគេផ្ងូតទឹកគុ្សល៍-ម៉ាយិត ។ ក៏ប៉ុន្តែ តើប៉ែកណាខ្លះ ក្នុងចំណោមប៉ែកខាងក្រោមនេះ ដែលនៅតែបរិសុទ្ធដាច់ឡែកពីទឹក គុ្សល៍-ម៉ាយិត ?

ក) សក់ និង ក្រចក ។

ខ) ធ្មេញ និង ឆ្អឹង ។

គ) ទាំងពីរខខាងលើនេះ ។

## លំហាត់ ៦

ចូរឆ្លើយសំណួរដោយជ្រើសរើសយកចម្លើយត្រឹមត្រូវ និងដោយសរសេរតួអក្សរតំណាងចម្លើយ ។

១. គុ្សល៍មួយណាមិនមែនគុ្សល៍វ៉ាយ៉ីប ?

ក) យجុមអعុតة់ ។
ខ) យ៉جុណាបាសة់ ។
គ) ណាសذ់រ៍(نذر) កقុស់ម៍(قسم) អាហهាដذ់(عهد) ។

២. ចំនួនគ្គុសល់រ៉ាយ៉ីបមាន៖

ក) ៥
ខ) ៣
ឃ) ៧

៣. ទឹកសម្រាប់គ្នុសល់ចាំបាច់ត្រូវ៖

ក) ត្រូហ្វៀរ មុតឡាក់និងមូបាស់ ។
ខ) ត្រូហ្វៀរ មុតឡាក់និងកុស់ប៊ី ។
គ) ត្រូហ្វៀរ មុតឡាក់និងមូដូហ្វ ។

៤. របៀបធ្វើ គុសល់ អៀរទីម៉ាស៊ី គឺ៖

ក) តាមតំណាក់ការ និងតាមលំដាប់ ។
ខ) លាងខ្លួនទាំងអស់តែម្តង ។
គ) ងូតទឹកធម្មតា ។

៥. ពេលបន្ទោបង់...

ក) និយាយជាទង្វើម៉ាក់រុះហ្វ ។
ខ) បែរមុខទៅរគ្គីបឡាត់ជាទង្វើហ្វារ៉ាំ ។
គ) ចម្លើយទាំងពីរខាងលើនេះជាចម្លើយត្រឹមត្រូវ ។

## លំហាត់ ៧

១. តើឈាមសត្វមានជីវិតបរិសុទ្ធឬណាយ៉ើស ? ហេតុអ្វី ?

ក) មនុស្ស
ខ) ពស់
គ) បាពពៃ

២. ដៃអ្នកទទឹក អ្នកចាប់ដៃបុគ្គលកាហៀ្យរ (ជាការគំនាប់) តើដៃអ្នកទៅជាណាយ៉ើសទេ ? ហេតុអ្វី ?

៣. ចូរបំពេញក្រឡាតារាងខាងក្រោមនេះ ។ ប=បរិសុទ្ធ ណ=ណាយ៉ើស ក=ក្តៅ ត្រ=ត្រជាក់ ។

| ពេល | សាកសព(ប ឬ ណ) | អ្នកប៉ះសាកសព (ប ឬ ណ) | សាកសព (ក ឬ ត្រ) |
|---|---|---|---|
| សាកសពក្រោយពីស្លាប់ភ្លាមៗ | | | |
| សាកសពក្រោយពីស្លាប់យូរ (មិនទាន់ផ្ងូតទឹកគ្មុសល់ម៉ាយិត) | | | |
| សាកសពក្រោយពីស្លាប់យូរ (ផ្ងូតទឹកគ្មុសល់ ម៉ាយិតហើយ) | | | |

៤. បើអ្នកប៉ះសាកសព (បន្ទាត់ទី២ ជួរបញ្ឈរទី២) វ៉ាយ៉ើបឲ្យអ្នកងូតទឹកគ្មុសល់________ ។

៥. តើអ្នកត្រូវលាងជម្រះបែបណាក្រោយពីបានបត់ជើងតូចរួចក្នុងបង្គន់ (បុរសត្រូវ

អធិប្បាយពន្យល់របៀបធ្វើអ៊ីសទីបរ៉អ៊ុំដែរ) ។

៦. អ៊ីសទីបរ៉អ៊ុំមានអត្ថប្រយោជន៍អ្វីខ្លះ (សម្រាប់តែបុរសទេ) ?

## លំហាត់ ៨ និង ៩

ចូរឆ្លើយសំណួរដោយជ្រើសរើសយកចម្លើយត្រឹមត្រូវ និងដោយសរសេរតួអក្សរតំណាងចម្លើយ ។

១. ទឹកមួយណាជាទឹកមុតឡាក់ ?

ក) ទឹកហូរ ។
ខ) ទឹកអណ្តូង ។
គ) ទឹកភ្លៀង ។
ឃ) ចម្លើយទាំងបីខាងលើជាចម្លើយត្រឹមត្រូវ ។

២. ហៅថាអាងទឹក "គូរ" គឺត្រូវមានប៉ែកខាង ពោលគឺ បណ្តោយ ទទឹង និង កំពស់ មានប្រវែងយ៉ាងហោចណាស់ស្មើនឹង...

ក) ២៣ សង់ទីម៉ែត្រ (២ តឹក) ។
ខ) ៦៩ សង់ទីម៉ែត្រ (៦ តឹក) ។
គ) ៧៦ សង់ទីម៉ែត្រ (៧ តឹក) ។
ឃ) ចម្លើយទាំងបីខាងលើនេះជាចម្លើយត្រឹមត្រូវ ។

៣. ខ្លួនអ្នកត្រូវណាយ៉ីសទឹកនោម ។ ដើម្បីជម្រះបន្សុទ្ធអ្នកត្រូវលាងសម្អាតយ៉ាងហោចណាស់...

ក) មួយដងជាមួយទឹកនឹងដែលមានចំនួនលើសពីមួយ "គូរ" ឬ ពីរដងជាមួយទឹកនឹងដែលមានចំនួនតិចជាងមួយ "គូរ" ។

ខ) ពីរដងជាមួយទឹកនឹងដែលមានចំនួនលើសពីមួយ "គូរ" ឬ មួយដងជាមួយទឹកនឹងដែលមានចំនួនតិចជាងមួយ "គូរ" ។

គ) មួយដងជាមួយទឹកនឹងដែលមានចំនួនលើសពីមួយ "គូរ" ឬ ពីរដងជាមួយទឹកនឹងដែលមានចំនួនតិចជាងមួយ "គូរ" ។

ឃ) បីដងជាមួយទឹកនឹងដែលមានចំនួនលើសពីមួយ "គូរ" ឬ បីដងជាមួយទឹកនឹងដែលមានចំនួនតិចជាងមួយ "គូរ" ។

៤. ទឹកដែលប្រែពណ៌ ប្រែរសជាតិ និងប្រែក្លិនជាទឹក...

ក) មុតឡាក់ ។
ខ) បរិសុទ្ធ
គ) មូដ្ឋហ៍
ឃ) ណាយ៉ីស

៥. វត្ថុខាងក្រោមនេះ (ដែលត្រូវណាយ៉ីស) មិនអាចជម្រះបន្សុទ្ធដោយពន្លឺថ្ងៃផ្ទាល់បានទេ គឺ៖

ក) ដើមឈើ ។
ខ) ដី ។
គ) សំលៀកបំពាក់ដាក់ហាល ។
ឃ) ជញ្ជាំង ។

៦. ឧទាហរណ៍ពាក់ព័ន្ធនឹងដំណើរការរបស់អ៊ីនគីឡាប់ គឺ៖

ក) ជំបងត្រូវណាយ៉ីសដែលទៅជាផេះ ។
ខ) ស្រាដែលត្រូវចម្រាញ់ទៅជាទឹកខ្មេះ ។
គ) សាកសពឆ្កែទៅជាដី ។

ឃ) សាកសពឆ្កែទៅជាអំបិលព្រោះវាស្លាប់នៅក្នុងស្រែឬអណ្តូងអំបិល ។

៧. តើអ៊ីសទីហ្ការឡាស្ហ៍(إستحالة)និងអ៊ីនគ្ហ៊ីឡាប់ខុសគ្នាត្រង់ណា ?

ក) សម្រាប់អ៊ីសទីហ្ការឡាស្ហ៍ សណ្ឋាននិងទិដ្ឋភាពផ្លាស់ប្តូរ ។ ឯអ៊ីនគ្ហ៊ីឡាប់វិញគុណភាពផ្លាស់ប្តូរ ។

ខ) សម្រាប់អ៊ីនគ្ហ៊ីឡាប់ សណ្ឋាននិងទិដ្ឋភាពផ្លាស់ប្តូរ ។ ឯអ៊ីសទីហ្ការឡាស្ហ៍វិញគុណភាពផ្លាស់ប្តូរ ។

គ) សម្រាប់អ៊ីសទីហ្ការឡាស្ហ៍ គឺពាក់ព័ន្ធនឹងវត្ថុត្រូវណាយ៉្ជីស ។ ឯអ៊ីនគ្ហ៊ីឡាប់វិញគឺពាក់ព័ន្ធនឹងសត្វមានជីវិត ។

ឃ) មិនខុសគ្នាទេ ។

៨. ពេលមូសបឺតឈាមអ្នក អ្នកវាយវាស្លាប់ (ឈាមប្រឡាក់ដៃអ្នក) ។ ឈាមនេះបរិសុទ្ធបើមានលក្ខខណ្ឌដូចតទៅគឺៈ

ក) អ្នកនៅស្រុកអាហ្វ្រិក ។
ខ) មានរយៈពេលមួយដែលឈាមនោះក្លាយទៅជាឈាមរបស់មូស ។
គ) អ្នកអាចមានជម្ងឺដោយសារមូសនោះខាំ ។
ឃ) ឈាមតិច ។

៩. បុគ្គលមិនមែនមុស្លីមទៅជាមុស្លីម ពេលបុគ្គលនោះ...

ក) ចាប់ផ្តើមបំពេញស្ហ្ស៍ឡាត្ហ៍ប្រចាំថ្ងៃទាំង ៥ ។
ខ) មានសទ្ធាចំពោះអល់ឡោះហ្ស៍តែមួយគត់ និងជឿព្រះសាស្តាទាំងឡាយ ។
គ) សូត្រកាលីម៉ាស្ហ៍ដោយសទ្ធាស្មោះ ។
ឃ) វាក្យសម្ពន្ធ ខ) និង គ) ជាចម្លើយត្រឹមត្រូវ ។

១០. ពេលបុគ្គលមិនមែនមុស្លីមទៅជាមុស្លីម ក្នុងចំណោមអ្នកខាងក្រោមនេះ តើអ្នកណាទៅជាមុស្លីមដោយស្វ័យប្រវត្ត ?

ក) កូនៗរបស់បុគ្គលនោះដែលបាលិគ្គ (គឺគ្រប់អាយុ) ។
ខ) ឪពុកម្ដាយរបស់បុគ្គលនោះ ។
គ) កូនៗរបស់បុគ្គលនោះដែលមិនទាន់បាលិគ្គ (គឺមិនទាន់គ្រប់អាយុ) ។
ឃ) បងប្អូនប្រុសស្រីរបស់បុគ្គលនោះ ។

១១. ពេលអណ្តូងទឹកត្រូវណាយ៉ិស គេធ្វើឲ្យវាទៅជាបរិសុទ្ធដោយយោងទឹកចេញមួយចំនួន ជញ្ជាំងអណ្តូងទឹកនេះ ខ្សែវានិងធុងដែលគេប្រើសម្រាប់ដួសទឹកទៅជាបរិសុទ្ធដែរជាស្វ័យប្រវត្ត ។ នេះគឺឧទាហរណ៍មួយរបស់...

ក) ស្ញាវ៉ាល់ អាល់-អ៊ៃន៍
ខ) អ៊ីសទីបរ៉អ៍
គ) តាបាអ៊ីយ៉ាស្ញ
ឃ) អ៊ីសទីហ្លាឡាស្ញ

១២. ប្រសិនបើមានឈាមក្នុងមាត់ ឬ លើច្រមុះ មាត់និងច្រមុះនឹងស្អាតដោយ...

ក) លាងជាមួយទឹកពីរដង ។
ខ) លាងជាមួយទឹកបីដង ។
គ) លាងជាមួយទឹកតែមួយដង ។
ឃ) យកឈាមចេញ ។ មិនបាច់លាងទេ ។

១៣. ចានត្រូវណាយ៉ិសស្រា អ្នកត្រូវលាងសម្អាតវាជាមួយទឹកតិចជាងមួយគួរ ឬជាមួយទឹកលើសពីមួយគួរ...

ក) បីដង ។

ខ) ពីរដង ។

គ) មួយដង ។

ឃ) ច្រើនដងស្រេចតែអ្នក ។

១៤. សត្វហ្ាឡាល់ត្រូវសំឡេះស្របតាមច្បាប់ស្ហារីអ៊ាស់(شريعة) ។ បរិមាណឈាមវាជាធម្មតា ។ ឈាមដែលនៅសល់ក្នុងខ្លួនវាជា...

ក) ឈាមបរិសុទ្ធ ។

ខ) ឈាមណាយ៉ីស ។

គ) ឈាមគួរ ។

ឃ) ឈាមហ្ារ៉ាំ ។

១៥. អ្នកឃើញសំលៀកបំពាក់របស់មុស្លីមទៅជាណាយ៉ីស ។ ក្រោយមក អ្នកឃើញគាត់ពាក់សំលៀកបំពាក់ដដែលបំពេញស្វ៉ឡាត់ ។ អ្នកអាចគិតថាគាត់បានជម្រះបន្សុទ្ធវាហើយ ដោយអាស្រ័យលើលក្ខខណ្ឌ គឺ៖

ក) គាត់ជាអ្នកគោរពច្បាប់ស្ហារីអ៊ាស់យ៉ាងខ្ជាប់ខ្ជួន ។

ខ) គាត់បានអវត្តមានយូរគ្រាន់បើ ដើម្បីមានពេលជម្រះបន្សុទ្ធសំលៀកបំពាក់នោះ ។

គ) វាក្យសម្ពន្ធ ក) និង ខ) ជាចម្លើយត្រឹមត្រូវ ។

ឃ) អ្នកឃើញគាត់សម្អាតសំលៀកបំពាក់គាត់ ។

## លំហាត់ ១០

ព្រះសាស្តាមូហ្ាំម៉ាដ់ﷺយើងមានព្រះវចនៈថាថ្ងៃសុក្រ ជាថ្ងៃល្អលើសថ្ងៃទាំងអស់នៃសប្តាហ៍ ។ ធ្វើទង្វើល្អមួយក្នុងថ្ងៃនេះបានរង្វាន់ច្រើន ។ គេនឹងទទួលយកស្វ៉ឡាត់ភ្លាមៗក្នុងថ្ងៃនេះ ។ ថ្ងៃសុក្រពិតជាថ្ងៃរបស់មុស្លីម ។ ពរជ័យសិរីសួស្តីដែលយើងអាចទទួលបានក្នុងថ្ងៃនេះមានច្រើនអនេក ។ អល់ឡោះហ្ﷻបានចាត់ទុកនគរម៉ាក់កាស់ជាកន្លែលមួយដែលពិសេសពិសាលដាច់អស់កន្លែងឯទៀតក្នុងលោក ព្រះអង្គﷻ

បានចាត់ទុកខែរ៉ម៉ាដូនប្រសើរជាច់អស់ខែឯទៀត ព្រះអង្គﷻបានចាត់ទុកថ្ងៃសុក្រប្រសើរជាច់អស់ថ្ងៃឯទៀត ។

ក) ថ្ងៃនេះ ម៉ាក់ស៊្វូមីន ៦ អង្គ ក្នុងចំណោមម៉ាក់ស៊្វូមីនទាំង ១៤ អង្គعليهم السلام បានចាប់កំណើត ។ ចូរសរសេរព្រះនាមម៉ាក់ស៊្វូមីនទាំង ៦ អង្គនេះដែលបានចាប់កំណើតក្នុងថ្ងៃដ៏ឱឡារិកនេះ ?

ខ) តើគេហៅថាអ្វី ស៊ុីយ៉ារ៉ត់ដែលគេសូត្រជាពិសេសក្នុងថ្ងៃសុក្រ (ក្រោយស្វ៍ឡាត់ថ្ងៃសុក្ររួច) ? ហេតុអ្វីយើងសូត្រស៊ុីយ៉ារ៉ត់នេះថ្ងៃសុក្រ ? (យើង មុស្លីមស្ទីអាស្ញ៉ រង់ចាំព្រឹត្តិការណ៍ធំមួយដែលនឹងកើតឡើងក្នុងថ្ងៃសុក្រ) ។

គ) តើគេហៅស្ពានពិធី (គឺគ៉ុស៊្វល គឺការងូតទឹកសម្អាតកាយ) ដែលគេធ្វើក្នុងថ្ងៃនេះថាអ្វី (គ៉ុសល៍អ្វី) ? តើស្ពានពិធីនេះជាវាយ៊ីប ឬ ជាស៊្វណាត់ ?

ឃ) ប្រទេសមុស្លីមភាគច្រើនចាត់ទុកថ្ងៃនេះជាថ្ងៃបុណ្យ (អ៊ុីដ្ធ) ។ ចូរលើកឡើងនូវទង្វើ ៣ ដែលយើងធ្វើក្នុងថ្ងៃបុណ្យ ហើយដែលយើងអាចធ្វើបានក្នុងថ្ងៃសុក្រដែរ (យើងអាចធ្វើទង្វើទាំងនេះបានក្នុងពេលផ្សេង តែគេផ្ដែផ្ដាំថាល្អបំផុតចូរធ្វើទង្វើទាំង ៣ នេះក្នុងថ្ងៃសុក្រ ឬថ្ងៃបុណ្យ (អ៊ុីដ្ធ)) ។

ង) ខាងក្រោមនេះគឺឈ្មោះចំនួន ១០ របស់ថ្ងៃសុក្រ ។ ចូរគូសឈ្មោះថ្ងៃសុក្រនៅខាងឆ្វេងភ្ជាប់ទៅរកន័យត្រឹមត្រូវរបស់វានៅខាងស្ដាំ ។

| | |
|---|---|
| យ៉ៅមុល ម៉ៅលុដ្ធ | ថ្ងៃធមិ |
| យ៉ៅមុល ហ្វាស្វ៉ល៍ | ថ្ងៃទទួលស្វ៍ឡាត់ |
| យ៉ៅមុល បារកាត់ | ថ្ងៃកិត្តិយស |
| យ៉ៅមុល ព៉ោះហ្វ៍ម៉ាស៊្វ | ថ្ងៃសាកល្បង |
| យ៉ៅមុល អ៊ុីយ៉ាប៊ុត | ថ្ងៃកំណើតព្រះសាស្ដាﷺ |
| យ៉ៅមុល អ៊ុីដ្ធ | ថ្ងៃសម្បូរ |
| យ៉ៅមុល អ៊ុីសក្វ៍ | ថ្ងៃមេត្តាប្រណី |

យ៉ៅមុល កុស្ញ់រ៉ាស្ញ់ ថ្ងៃពរជ័យ
យ៉ៅមុល ការ៉ម៉ាត់ ថ្ងៃអត់ឱន
យ៉ៅមុល ម៉ាស្ទ៊ីដ្ញ ថ្ងៃបុណ្យ

## លំហាត់ ១១

ក) ចូរអានសម្រាយស្ញូរ៉េាះត្ញ៉ ឃ្ញុមអ្ញុត្ញ់ (៦២) ក្នុងព្រះគម្ពីរគ្នូរអាន ។ ចូរស្វែងរកអាយ៉ាស្ញ់ដែលស្តីអំពីស្ញ៉ទ្បាត្ញ់ឃ្ញុមអ្ញុត្ញ់ក្នុងស្ញូរ៉េាះត្ញ៉នេះ ។

ខ) តើស្ញ៉ទ្បាត្ញ់ឃ្ញុមអ្ញុត្ញ់ខុសពីស្ញ៉ទ្បាត្ញ់ធម្មតាត្រង់ណាខ្លះ ? ចូរផ្តល់នូវបីខសំអាង ។

គ) តើគេបំពេញស្ញ៉ទ្បាត្ញ់ឃ្ញុមអ្ញុត្ញ់បែបណា ?